ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានស្រាវជ្រាវនិងនវានុវត្តន៍

OPEN ACCESS

ទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម
Cambodian Journal of Education and STEM

## អត្ថបទស្រាវជ្រាវ ( Original Article )

# ការអនុវត្តសេវានិស្សិតក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា៖ ករណីសិក្សាគ្រឹះស្ថានឧត្តមសិក្សារដ្ឋ

# The Practice of Student Services in Cambodia: A Case Study of Public Higher Education Institutions

មឿន ចន្ទ្រា [១,*] សំ ច័ន្ទភិរុណ [២] និង ម៉ុក សារ៉ុម [៣]

[១]សាកលវិទ្យាល័យភូមិន្ទភ្នំពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[២] វិទ្យាស្ថានជាតិគរុកោសល្យរាជធានីភ្នំពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៣]ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ប្រទេសកម្ពុជា

* អ្នកនិពន្ធទទួលបន្ទុកឆ្លើយឆ្លង៖ moeurn.chantrea.rupp@moeys.gov.kh

Chantrea Moeurn[1,*], Chanphirun Sam[2] Sarom Mok [3]

[1]Royal University of Phnom Penh, Phnom Penh, Cambodia

[2]Phnom Penh Teacher Education College, Phnom Penh, Cambodia

[3]Ministry of Education Youth and Sport, Phnom Penh, Cambodia

*Corresponding author: moeurn.chantrea.rupp@moeys.gov.kh

https://doi.org/10.62219/cjes.2025314

| | | |
|---|---|---|
| **ទទួលបានអត្ថបទ៖** ២៦ កញ្ញា ២០២៤ | **កែសម្រួល៖** ២៥ កុម្ភៈ ២០២៥ | **យល់ព្រមឱ្យបោះពុម្ព៖** ២១ មីនា ២០២៥ |
| **Received:** 26 September 2024 | **Revised:** 25 February 2025 | **Accepted:** 21 March 2025 |

**មូលន័យសង្ខេប**

សេវានិស្សិតត្រូវបានកំណត់ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការធានាគុណភាពអប់រំឧត្តមសិក្សា ដោយសារមុខងារ និងភារកិច្ចនៃសេវានេះ គឺមិនត្រឹមតែជួយគ្រឹះស្ថានឧត្តមសិក្សាឱ្យសម្រេចបេសកកម្មប៉ុណ្ណោះទេ ថែមទាំងជាចំណែកជួយឱ្យនិស្សិតទទួលបានជោគជ័យលើការសិក្សាបន្ថែមទៀត។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអាណាព្យាបាលបច្ចេកទេសបានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត យន្តការផ្តល់សេវា និងសកម្មភាពគាំទ្រផ្សេងៗជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់គុណភាពសេវានិស្សិត។ ទន្ទឹមនេះ ការស្រាវជ្រាវជាច្រើនបានរកឃើញថា

ភាពជោគជ័យលើការសិក្សារបស់និស្សិតនៅគ្រឹះស្ថានឧត្តម គឺផ្អែកលើកត្តាសុខភាពល្អ ស្វ័យសិក្សា គោលដៅច្បាស់លាស់ ការប្រឹក្សាទាន់ពេល និងការលើកទឹកចិត្តជាដើម។ សារប្រយោជន៍នៃសេវានិស្សិតបានចូលរួមបង្កើនមូលធនមនុស្សសម្រាប់ប្រទេសជាតិ តែសេវានិស្សិតទាមទារជាចាំបាច់ឱ្យមានការចូលរួមជិតស្និទ្ធ ពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ការប្តេជ្ញាចិត្តខ្ពស់ និងកិច្ចសហការស្អិតល្មួត។ ស្របជាមួយគ្នានេះ គ្រឹះស្ថានឧត្តមសិក្សាយកចិត្តទុកដាក់ខ្លាំងលើសេវានិស្សិតបានជួយបំពេញដល់តម្រូវការក្នុងការអភិវឌ្ឍ និងការសិក្សារបស់និស្សិត។ ជាពិសេស គ្រឹះស្ថានទទួលបានទំនុកចិត្តពីនិស្សិត និងភាគីពាក់ព័ន្ធកាន់តែខ្ពស់ និងឈានទៅទទួលបាននូវស្ថេរភាពហិរញ្ញវត្ថុ និងការទទួលស្គាល់គុណភាពនៅកម្រិតបន្ទាប់។ ប៉ុន្តែការអនុវត្តសេវានិស្សិតនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសកម្ពុជាពុំទាន់មានការសិក្សាស្រាវជ្រាវឱ្យបានទូលំទូលាយ និងពេញលេញនៅឡើយ។ ដោយសារសារប្រយោជន៍ និងភាពចាំបាច់នៃសេវានិស្សិតក្នុងគ្រឹះស្ថានឧត្តមសិក្សា គោលបំណងនៃការស្រាវជ្រាវគឺ ដើម្បីរកឱ្យឃើញពីស្ថានភាពអនុវត្តសេវានិស្សិតក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា និងអនុសាសន៍ក្នុងការពង្រឹងគុណភាពសេវានិស្សិត។ ការស្រាវជ្រាវបែបគុណវិស័យត្រូវបានជ្រើសរើស ដោយប្រើប្រាស់ការសម្ភាស ដែលមានមានអ្នកចូលរួមចំនួន ៣២ នាក់។ ការសម្ភាសនេះបានបែងចែកជាពីរគឺការសម្ភាសម្នាក់ទល់ម្នាក់ជាមួយអ្នកដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សា។ ចំណែកការសម្ភាសជាក្រុមបានរៀបចំឡើងជាមួយនិស្សិត។ លទ្ធផលស្រាវជ្រាវបង្ហាញថា ការអនុវត្តសេវានិស្សិតនៅកម្ពុជាជួបបញ្ហាប្រឈមចំនួនពីរគឺកម្រិតក្រសួងអាណាព្យាបាលបច្ចេកទេស ដោយមានយន្តការវាយតម្លៃស្ម័គ្រចិត្ត និងការអនុវត្តលើការធ្វើប្រតិភូកម្មអំណាចមិនទាន់ពេញលេញ។ ចំណែកកម្រិតគ្រឹះស្ថានឧត្តមសិក្សាជួបប្រទះបញ្ហាដូចជាប្រព័ន្ធផ្តល់សេវា ធនធានមនុស្ស ការធ្វើទំនើបកម្មសេវា និងថវិកាទ្រទ្រង់។ បន្ថែមពីនេះ ការស្រាវជ្រាវក៏បានរកឃើញពីលក្ខណសម្បត្តិនៃសេវានិស្សិតត្រូវរួមមាន៖ រចនាសម្ព័ន្ធនិងធនធានមនុស្ស យន្តការច្រកចេញចូលតែមួយ ថវិកាទ្រទ្រង់ និងការចូលរួម។ ផ្អែកតាមលទ្ធផលស្រាវជ្រាវនេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវយកចិត្តទុកដាក់ខ្ពស់ទៅលើសេវានិស្សិត និងធ្វើទំនើបកម្មដោយប្រើប្រាស់បច្ចេកវិទ្យាលើសេវានេះ ដើម្បីធានាដល់ស្ថេរភាពសុខភាពហិរញ្ញវត្ថុគ្រឹះស្ថាន និងទំនុកចិត្តពីគ្រប់ភាគីពាក់ព័ន្ធ។

**ពាក្យគន្លឹះ៖** ការអនុវត្ត សេវានិស្សិត គ្រឹះស្ថានឧត្តមសិក្សា យន្តការ ច្រកចេញចូលតែមួយ

**Abstract**

Student services are widely acknowledged as a cornerstone of higher education quality, playing a vital role in enabling institutions to achieve their strategic objectives and fostering student success. The Royal Government and relevant ministries have established formal policies and mechanisms, as well as support activities to strengthen student services in Cambodia. Research consistently highlights successful students demonstrating good health, effective self-study habits, clear goal-setting, timely access to guidance, and high motivation levels. Developing human capital

that aligns with societal demands necessitates the active engagement of all stakeholders, strong commitment, and cohesive collaboration. Higher education institutions (HEIs) that prioritize robust student services contribute to cultivating human capital and addressing the diverse needs of their student populations. By doing so, they build trust among stakeholders and students, ultimately enhancing financial sustainability and positioning themselves for potential quality recognition and accreditation. This study examines the current state of student services in Cambodian higher education institutions and offers actionable recommendations for improving service quality. Using a qualitative research methodology, the study involved semi-structured interviews with a purposive sample of 32 participants, including senior management from relevant agencies and HEIs, as well as focus group discussions with students. The findings indicate that student services in Cambodian HEIs often receive insufficient attention due to systemic challenges. At the national level, voluntary evaluation practices and delegated responsibilities hinder progress, while institutional challenges include underdeveloped service systems, limited human resources, outdated practices, and constrained budgets. The study underscores the importance of implementing key measures for effective student services, such as well-structured human resources, integrated one-stop service models, sufficient budgetary support, and active stakeholder involvement. Modernizing student services through digital technology is strongly recommended to improve operational efficiency, ensure financial stability, and bolster stakeholder confidence.

**Keywords:** Student service; higher education institutions; mechanism; one-window service

## សេចក្តីផ្តើម

គ្រឹះស្ថានឧត្តមសិក្សា សំដៅដល់មជ្ឈមណ្ឌលអប់រំដែលផ្តល់ការអប់រំបណ្តុះបណ្តាលជំនាញឯកទេស កម្រិតក្រោយមធ្យមសិក្សា (Kingdom of Cambodia, 2007) ។ គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាក្រោយសម័យអង្គរពុំឃើញមានការនិយាយ និងចងក្រងឱ្យបានដឹងពីស្ថានភាពនៃការបណ្តុះបណ្តាលកម្រិតខ្ពស់ក្នុងប្រទេសកម្ពុជានោះឡើយ។ អ្វីដែលយើងបានដឹង និងទទួលបាននោះគឺការអប់រំសម័យកណ្តាលមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយវត្តអារាម រហូតដល់ការនិយាយថា «សាលាវត្ត» យ៉ាងរត់មាត់ ដោយព្រះសង្ឃគឺជាអ្នកបង្រៀន (Ayres, 2000) ។ ស្របគ្នានេះ Clayton (1998) បានលើកឡើងផងដែរថាការអប់រំនេះសម័យនោះពុំមានកំណត់កម្រិតថ្នាក់ កាលវិភាគសិក្សាច្បាស់លាស់ និងការចុះពិនិត្យនិងវាយតម្លៃ ខណៈការបណ្តុះបណ្តាល គឺដើម្បីទទួលបានចំណេះដឹងជាមូលដ្ឋានដូចជាការសរសេរ ការចេះលេខនព្វន្ត ក្នុងគោលដៅសម្រួលជីវភាពរស់នៅប្រចាំថ្ងៃ។ នៅសម័យឧត្តុង្គ យើងឃើញមានការចងក្រង និង

និយាយពីសាកលវិទ្យាល័យមួយមានទីតាំងនៅរាជធានីឧត្តុង្គ ដោយបានបញ្ជាក់ថា ព្រះបាទអង្គឌួងជាក្សត្រដែលមានស្នាដៃ និងភាពល្បីល្បាញ គឺជាសាកលវិទ្យាធិការ (Yong & Sorn, 1999)។

វត្តមានគ្រឹះស្ថានឧត្តមសិក្សាទំនើបរបស់កម្ពុជាបានលេចចេញជារូបរាងឡើង ក្នុងសម័យអាណានិគមបារាំងគឺនៅឆ្នាំ១៩៤៩ តាមរយៈការបង្កើតវិទ្យាស្ថានជាតិវិទ្យាសាស្ត្រនយោបាយ សេដ្ឋកិច្ច និងច្បាប់ (Houn, 1974; MoEYS, 2024c)។ ស្ថានភាពសង្គមកម្ពុជាមានការប្រែប្រួលរបបនយោបាយជាញឹកញាប់ ឈានទៅធ្វើឱ្យអនុវិស័យឧត្តមសិក្សា កម្ពុជាមានការកើនឡើង ហើយបាត់បង់ទៅវិញ និងឈានត្រឡប់មកឡើងជាថ្មី មិននឹងនរ ពុំទាន់មានស្ថេរភាព។ វត្តមានគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាបានដាច់ដាកង់ៗ ទៅតាមស្ថានភាពនយោបាយ ( Un & Sok, 2018)។ ការទន្ទឹងរង់ចាំសន្តិភាពរបស់ប្រជាជនកម្ពុជាបានមកដល់ គឺនៅចុងឆ្នាំ១៩៩៨ តាមរយៈការអនុវត្តនយោបាយឈ្នះឈ្នះរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** (Pov, 2024)។ លទ្ធផលនេះសុខសន្តិភាព ការអប់រំពេញលេញបានរីកចម្រើនកាន់តែខ្លាំង និងផ្តល់ឱកាសដល់សិស្ស និស្សិតទទួលបានឱកាសសិក្សាដូចៗគ្នា។

លើសពីនេះទៅទៀតចំនួនគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាបានកើនឡើងយ៉ាងគំហុក ស្របពេលដែលចំនួននិស្សិតក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ តួយ៉ាង ចំនួននិស្សិត និងគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនកម្ពុជាបានកើនឡើងយ៉ាងគំហុក គឺនៅឆ្នាំ២០១៣ ប្រទេសកម្ពុជាមានគ្រឹះស្ថានឧត្តមសិក្សាតែ ១០៥ ប៉ុណ្ណោះ និងឈានដល់ ១៨៩ គ្រឹះស្ថានឧត្តមសិក្សា (រូបភាពទី១)ដែលស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងចំនួន១៧ (MoEYS, 2024a, 2024b)។




*រូបភាពទី១៖* ចំនួនគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា 2013-2024 (MoEYS, 2024a)

វត្តមានឧត្តមសិក្សាដើរតួនាទីសំខាន់ណាស់ក្នុងការបង្កើតពុទ្ធិនៃមូលធនសកម្ម និងជាប្រភពនៃទ្រព្យធន និងវិបុលភាព ដើម្បីរួមចំណែកពេញលេញក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិទាំងក្នុងពេលបច្ចុប្បន្ន និងពេលអនាគត (MoEYS, 2014)។ ដើម្បីបង្កើនគុណភាពអប់រំនៅឧត្តមសិក្សា រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការវាយតម្លៃគុណភាពអប់រំនៅកម្ពុជា (គទក ឬ ACC) សំដៅជាយន្តការគាំទ្រ និងវាយតម្លៃលើការបណ្តុះបណ្តាលក្នុងកម្រិតឧត្តមសិក្សា។ គទក បាន

ចេញសេចក្តីសម្រេច និងសេចក្តីណែនាំជាបន្តបន្ទាប់ដល់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដើម្បីធានាដល់ការបណ្តុះបណ្តាលរបស់គ្រឹះស្ថានឆ្លើយតបទៅនឹងតម្រូវការនិស្សិត និងទីផ្សារការងារ និងឈានទៅស្របតាមស្តង់ដាជាតិ និងតំបន់។ ស្តង់ដាអប្បបរមាសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជាបានរៀបចំឡើង (ACC, 2009, 2015) និងសេចក្តីណែនាំស្តីពីការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា (ACC, 2023)។ សេវានិស្សិតត្រូវបានកំណត់ជាផ្នែកសំខាន់មួយក្នុងគ្រឹះស្ថានឧត្តមសិក្សាដោយមានមេគុណ៣។ ទន្ទឹមនេះ ACC (2018 )បានលើកឡើងថា សេវានិស្សិតសំដៅផ្តល់បរិយាកាសងាយស្រួល ទាំងសម្បទា ស្មារតី វិជ្ជាសម្បទា និងវប្បធម៌ឱ្យឆ្លើយតបទៅនឹងតម្រូវការនិស្សិត។ ស្របជាមួយគ្នានេះ National Association of Student Personnel Administrators ឬ NASPA (2012) ក៏បានបញ្ជាក់ថាសេវានិស្សិតសំដៅដល់ផ្នែកមួយដែលផ្តល់សេវាកម្មផ្សេងៗ និងផ្តល់ការគាំទ្រដល់និស្សិតនៅកម្រិតឧត្តមសិក្សា ក្នុងគោលដៅធានាដល់ការអភិវឌ្ឍ និងការរីកចម្រើនរបស់និស្សិតអំឡុងពេលនៅសិក្សា។

កំណើននិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សា (រូបភាពទី២) ជាចំណុចសំខាន់មួយដែលគ្រឹះស្ថានត្រូវផ្តល់ការគាំទ្រគ្រប់លទ្ធភាព និងរូបភាព ស្របពេលដែលនិស្សិតមានកម្រិតជីវភាព ចំណេះដឹង និងជំនាញទន់មិនដូចគ្នា។ កត្តានេះសេវានិស្សិតមានមុខងារជួយនិស្សិតទទួលបានការបណ្តុះបណ្តាលដោយជោគជ័យ និងកម្រិតចំណេះដឹងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។ តួយ៉ាង UNESCO (2002) បានលើកឡើងថាសេវានិស្សិតគឺជួយជំរុញឱ្យនិស្សិតចូលរួមកាន់តែសកម្មក្នុងកិច្ចការសង្គម។ ក្រៅពីទំនាក់ទំនងផ្ទាល់ជាមួយគ្រូបង្រៀនក្នុងថ្នាក់ និស្សិតទទួលបានឱកាសក្នុងការចូលរួមជាមួយដៃគូពាក់ព័ន្ធ ដែលបានរួមចំណែកផ្តល់ទាំងធនធានចំណេះដឹងជំនាញ និងបទពិសោធក្នុងការងារសហគមន៍តាមរយៈការចូលរួមការងារស្ម័គ្រចិត្ត និងហាត់ការរយៈពេលខ្លីជាដើម។ ការផ្តល់សេវាគាំទ្រ និងសកម្មភាពជំនួយផ្សេងៗទៀតក៏គួរតែរៀបចំឱ្យសមស្របទៅតាមការវិវត្ត និងការប្រែប្រួលរបស់គ្រឹះស្ថាននិងទីផ្សារការងារផងដែរ។ ទន្ទឹមនេះ Ciobanu (2013)ក៏បានរកឃើញថាកម្មវិធីខ្លះត្រូវកែសម្រួល និងបន្ថែមសកម្មភាពទើបអាចឆ្លើយតបទៅនឹងតម្រូវការរបស់និស្សិតបាន។




*រូបភាពទី២៖* និស្សិតសិក្សាថ្នាក់បរិញ្ញាបត្រនៅឧត្តមសិក្សាក្រោមក្រសួងអប់រំ យុវជន និងកីឡា ((MoEYS, 2024a)

ផ្ទុយទៅវិញ គ្រឹះស្ថានដែលពុំបានយកចិត្តទុកដាក់ និងផ្តល់សេវាគាំទ្រនិស្សិតបានទាន់ពេលវេលា និងត្រឹមត្រូវ គឺជាកត្តារួមចំណែកឱ្យនិស្សិតបោះបង់ការសិក្សានិងពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ។ NationalYouth Development Council & UNFPA (2000) បានបង្ហាញថា ភាពក្រីក្រ ភាពងាយរងគ្រោះ ការមិនបានទទួលការលើកទឹកចិត្តដោយសាររៀនយឺត ការយល់ឃើញរបស់ឪពុកម្តាយអំពីសារៈសំខាន់នៃការអប់រំរបស់កូន ភាពទាក់ទាញនៃការទទួលបានការងារធ្វើ ជាពិសេសការយល់ឃើញរបស់សិស្ស។ លទ្ធផលនៃការស្រាវជ្រាវខាងលើនេះក៏បានបន្ថែមទៀតថា " គុណភាពអប់រំជាបញ្ហាមួយ ដោយបញ្ជាក់ថា សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សាពុំមានសមត្ថភាពពេញលេញក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមហ៊ុន ដោយពួកគេមានគម្លាតជំនាញ" (ទំព័រទី១១)។ ស្របគ្នាជាមួយនឹង National Employment Agency (2000) បានបង្ហាញថា និយោជកបានប្រាប់ពីកង្វះខាតខ្លាំងលើជំនាញទន់សម្រាប់និយោជិតក្នុងការបំពេញការងារ ហើយអត្រាអ្នកបោះបង់ការងារខ្ពស់ ដោយសារកត្តាកង្វះខាតជំនាញទន់រួមមាន៖ ការងារក្រុម ការប្រាស្រ័យទាក់ទង ការដោះស្រាយបញ្ហាជាដើម។

ទន្ទឹមនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (2024) បានបង្ហាញថា ជំនាញទន់ចំនួន៧ គឺជាតម្រូវការទីផ្សារកម្ពុជាខ្ពស់រួមមាន៖ ជំនាញសម្របសម្រួលជាមួយអតិថិជន ជំនាញការងារជាក្រុម ជំនាញរៀនការងារថ្មីបានលឿន និងឆាប់ចេះ ជំនាញដោះស្រាយបញ្ហា ជំនាញទំនាក់ទំនង ជំនាញរៀបចំផែនការ និងជំនាញភាសាបរទេស។ ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ បញ្ចកោណទី៣ មុំទី១ផ្តោតលើ ការអភិវឌ្ឍវិស័យឯកជន និងការងារ។ ចំណុចទី២ នៃមុំទី១ បានបង្ហាញយ៉ាងច្បាស់នូវចេតនារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវផ្តោតលើការបន្តបង្កើនការងារ ការពង្រីកសេវាជួយស្វែងរកការងារ ប្រឹក្សាយោបល់ និងមគ្គុទេសន៍ការងារ ការបន្តរៀបចំវេទិកាការងារ និងរៀបចំឱ្យមានគ្រូបង្គោល និងជនបង្គោលផ្នែកអាជីពសម្រាប់ជួយស្វែងរកការងារ នៅតាមគ្រឹះស្ថានសិក្សា (Royal Government of Cambodia, 2023) ។ រដ្ឋត្រូវជំរុញនិងលើកទឹកចិត្តយុវជនក្នុងការអប់រំផ្តល់ បរិយាកាសទីផ្សារការងារដល់យុវជន លើកកម្ពស់ការបណ្តុះបណ្តាលជំនាញអាជីព បង្កើនការចូលរួមពេញលេញ ក្នុងស្ថាប័ននានា និងសហគមន៍ និងបង្កើនការចូលរួមការងារស្ម័គ្រចិត្តដល់យុវជនជាដើម (RGC, 2011)។ ខ្លឹមសារនេះគឺជាការចង្អុលបង្ហាញបន្ថែមទៀតឱ្យគ្រឹះស្ថានឧត្តមសិក្សា ដែលផ្តល់សេវានិស្សិតផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្ពស់បំផុត ជាពិសេសសេវាប្រឹក្សាលើអាជីព និងការងារដល់និស្សិត បន្ថែមពីការណែនាំក្នុងការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សាត្រង់ស្តង់ដាទី៥ (ACC, 2023)។

បន្ថែមពីនេះ UNESCO (1998) បានលើកឡើងថា គ្រឹះស្ថានឧត្តមសិក្សាគួរអប់រំនិស្សិតឱ្យក្លាយជាអ្នកមានចំណេះដឹង ពលរដ្ឋមានទំនុកចិត្តខ្ពស់ ដែលអាចគិតបានស៊ីជម្រៅ វិភាគបញ្ហាសង្គម ស្វែងរកដំណោះស្រាយ និងអនុវត្តវិធីសាស្ត្រ ជួយសង្គម និងទទួលយកទំនួលខុសត្រូវរបស់ខ្លួនចំពោះការងារសង្គម។ គ្រឹះស្ថានឧត្តមសិក្សាជាកន្លែងចម្រុះដែលបណ្តុំដោយអ្នកសិក្សា និងអ្នកបណ្តុះបណ្តាលមានប្រវត្តិផ្សេងៗគ្នាលើផ្នែក៖ សង្គមវប្បធម៌ នយោបាយ សាសនា និងពូជសាសន៍ជាដើម។ ភាពចម្រុះទាំងនេះពិតជាត្រូវការឱ្យអ្នកបណ្តុះបណ្តាលនិងនិស្សិតមានទំនាក់ទំនងល្អនឹងគ្នា ដើម្បីឈានទៅរកការបង្កើតបរិស្ថានសិក្សាមួយបានយ៉ាងល្អ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារផងដែរ (Chepchieng et al., 2006)។ ការស្រាវជ្រាវដដែលនេះបានបង្ហាញផងដែរថាទំនាក់ទំនងល្អរវាងនិស្សិតនិងគ្រូជាកត្តារួមចំណែកសំខាន់មួយ ដែលមានផលជះលើការសិក្សា អាកប្បកិរិយា និងការចូលរួមសកម្មភាពរបស់និស្សិតពេលនៅសាកលវិទ្យាល័យផងដែរ។

ស្របជាមួយគ្នាដែរ Whitt et al. (2001)បានបង្ហាញថា ទំនាក់ទំនងនិស្សិតជាមួយមនុស្សជុំវិញខ្លួន ដោយរួមទាំងទំនាក់ទំនងជាមួយដៃគូ និងទំនាក់ទំនងជាមួយគ្រូបង្រៀនបានផ្តល់នូវផលជះជាវិជ្ជមានលើការផ្លាស់ប្តូររបស់និស្សិតទៅលើការរំពឹងទុក តម្លៃ ឥរិយាបថ ជំនឿ និងសកម្មភាពរបស់ពួកគេ ។ ដូចគ្នាទៅនឹង Ngara (1995) បានរកឃើញថាទំនាក់ទំនងល្អរវាងនិស្សិតនិងគ្រូ ទាំងផ្លូវការ និងមិនផ្លូវការក្តី គឺធ្វើឱ្យគ្រូអាចផ្ទេរចំណេះដឹងនិងជំនាញរបស់គាត់បានច្រើនជាងការកំណត់ក្នុងកម្មវិធីសិក្សាថែមទៀតផង ។ ចំណែក Bjorklund et al. (2004) បានបង្ហាញថាទំនាក់ទំនងរបស់គ្រឹះស្ថាន និងការផ្តល់មតិស្ថាបនាទៅកាន់និស្សិតផ្តល់នូវផលជះជាវិជ្ជមានក្នុងការអភិវឌ្ឍសមត្ថភាពជំនាញរបស់និស្សិត។ កម្រិតបណ្តុះបណ្តាលកាន់តែខ្ពស់ ការទទួលបានប្រាក់ចំណូលក៏កាន់តែច្រើន ព្រមទាំងទទួលបានឱកាសការងារកាន់តែល្អប្រសើរ។ គ្រឹះស្ថានឧត្តមសិក្សាត្រូវធានាឱ្យបាននូវគុណភាព និងមានការទទួលស្គាល់ ដើម្បីឱ្យការបណ្តុះបណ្តាលឆ្លើយតបទៅនឹងការរំពឹងទុករបស់និស្សិត និងសេចក្តីត្រូវការរបស់សេដ្ឋកិច្ច និងសង្គមជាតិ។ ជាពិសេសការកើនឡើងនៃចំនួនគ្រឹះស្ថានឧត្តមសិក្សាកាន់តែប្រកួតប្រជែងនាពេលថ្មីៗនេះ កាន់តែធ្វើឱ្យគ្រឹះស្ថានបណ្តុះបណ្តាលកាន់តែត្រូវយកចិត្តទុកដាក់ និងផ្តល់សេវាឱ្យមានគុណភាពល្អ ព្រមទាំងការធ្វើអន្តរជាតូបនីយកម្មគ្រឹះស្ថានឧត្តមសិក្សាជាដើម (Mastio et al., 2019)។ បន្ថែមពីនេះ Selim and Muhammad (2014) បានបង្ហាញថាគុណភាពសេវានិស្សិតរបស់គ្រឹះស្ថានអប់រំមានសារៈសំខាន់ណាស់លើកម្មវិធីបណ្តុះបណ្តាល និងបានក្លាយជាកត្តាសំខាន់ក្នុងផែនការយុទ្ធសាស្ត្ររបស់ស្ថាប័នដើម្បីលើកកម្ពស់ដល់ការប្រកួតប្រជែងផងដែរ។

ប្រវត្តិនៃការបណ្តុះបណ្តាលកម្រិតឧត្តមមានការវិវត្តពុំសូវល្អតាមសម័យកាលជាបន្តបន្ទាប់ តែនៅចុងទសវត្សឆ្នាំ១៩៩០ គ្រឹះស្ថានឧត្តមសិក្សារដ្ឋត្រូវអនុញ្ញាតឱ្យទទួលបានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ តាមរយៈព្រះរាជក្រឹត្យស្តីពីការប្រែក្លាយទៅជាគ្រឹះស្ថានសាធារណរដ្ឋបាល (Un & Sok, 2018)។ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមយកចិត្តទុកដាក់លើការបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា។ ជាលទ្ធផល ចំនួនគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាចាប់ផ្តើមរីកចម្រើនជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០០០ តាមរយៈការបង្កើនចំនួននិស្សិតសិក្សានៅក្រៅប្រទេស ការចូលរួមជាមួយដៃគូក្នុងតំបន់ និងការចូលរួមបណ្តុះបណ្តាលទ្វេសញ្ញាបត្រជាមួយគ្រឹះស្ថានឧត្តមសិក្សាបរទេស (Sok & Bunry, 2024)។

ចំណែក Heng et al.(2023) បានរកឃើញថាស្ថិតក្នុងដំណាក់កាលនៃការលើកកម្ពស់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាបានប្រឈមបញ្ហាមួយចំនួនរួមមាន៖ ធនធាននិងហេដ្ឋារចនាសម្ព័ន្ធមានកំណត់ ឥទ្ធិពលនយោបាយ លទ្ធផលនៃការធ្វើឯកជនភាវូបនីយកម្មឧត្តមសិក្សា បុគ្គលិកអប់រំប្រាក់ខែទាប និងលទ្ធភាពក្នុងការបណ្តុះបណ្តាលអាជីពមានកំណត់។ ឆ្លើយតបទៅនឹងតម្រូវការសង្គម និងសេដ្ឋកិច្ចកម្ពុជា គ្រឹះស្ថានឧត្តមសិក្សាត្រូវការកំណែទម្រង់ ដើម្បីបង្កើនគុណភាព និងឆ្លើយតបនឹងស្ថានភាព (Heng & Sol, 2023)។ លទ្ធផលនៃការស្រាវជ្រាវនេះបានផ្តល់អនុសាសន៍កំណែទម្រង់មួយចំនួនរួមមាន៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កម្មវិធីសិក្សា ប្រព័ន្ធប្រាក់បៀវត្សអភិវឌ្ឍវិជ្ជាជីវៈ ការស្រាវជ្រាវ និងប្រព័ន្ធធានាគុណភាព។ ហេដ្ឋារចនាសម្ព័ន្ធសេវានិស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សាបន្តជាបញ្ហាសម្រាប់គ្រឹះស្ថានឧត្តមសិក្សា។ ដូចគ្នានេះ World Bank(2000)បានបង្ហាញថាគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍជួបប្រទះកង្វះហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារពិសោធន៍។ បន្ថែមពីនេះ World Bank (1997) ក៏បានលើកឡើងថាគ្រឹះស្ថានឧត្តមសិក្សាប្រទេសកំពុងអភិវឌ្ឍជួបបញ្ហាកង្វះខាតធនធានមនុស្ស និងប្រសិទ្ធភាពក្នុងការបំពេញការងារ។ ស្របគ្នានឹង Sandeen (1988) បានលើកឡើងថាបញ្ហាប្រឈមមួយផ្សេងទៀតគឺកង្វះការបណ្តុះបណ្តាលលើ

ជំនាញនិងវិជ្ជាជីវៈដល់បុគ្គលិកបម្រើការងារក្នុងផ្នែកនេះ។ រីឯ Heng (2024) បានរកឃើញថាការចាប់ផ្ដើមអភិវឌ្ឍការស្រាវជ្រាវនៅគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន។ សរុបមក អ្នកស្រាវជ្រាវកម្ពុជា និងបរទេសជាច្រើនរូបបានសិក្សាពីសាវតា បច្ចុប្បន្នភាព និងការអភិវឌ្ឍរបស់គ្រឹះស្ថានឧត្តមសិក្សានៅក្នុងប្រទេសកម្ពុជា ដើម្បីបង្ហាញពីសមត្ថភាព និងលទ្ធភាពជាក់ស្ដែងក្នុងការរួមចំណែកអភិវឌ្ឍមូលធនមនុស្ស ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលឆ្នាំ២០៥០។

ប៉ុន្តែមិនទាន់មានការស្រាវជ្រាវពីសេវានិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ណាមួយដែលត្រូវបានធ្វើឡើង ដើម្បីទទួលបានព័ត៌មានលម្អិតពីការអនុវត្តសេវានិស្សិតក្នុងគ្រឹះស្ថានឧត្តមសិក្សានោះទេ ខណៈលិខិតបទដ្ឋាន និងសេចក្ដីណែនាំពីការអនុវត្តសេវានិស្សិតទៀតសោត កាន់តែពុំសូវសំបូរបែប។ អ្នកស្រាវជ្រាវទាញការសន្និដ្ឋានដោយផ្អែកលើការស្រាវជ្រាវកន្លងទៅចំពោះប្រទេសកំពុងអភិវឌ្ឍន៍ និងបទពិសោធផ្ទាល់ខ្លួនក្នុងការបំពេញការងារក្នុងវិស័យឧត្តមសិក្សា១០ឆ្នាំជាងមក ថាការអនុវត្តសេវានិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាពុំទាន់បានពេញលេញ និងឆ្លើយតបទៅនឹងតម្រូវការនិស្សិត និងទីផ្សារការងារនោះឡើយ។ ការផ្ដល់សេវានិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍ ជួបប្រទះនូវបញ្ហាមួយចំនួន ស្របពេលសេវានិស្សិតត្រូវការប្រើប្រាស់ថវិកាច្រើន។ តួយ៉ាង World Bank (1994) បានរកឃើញថា វិស័យឧត្តមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍជួបបញ្ហាប្រឈមចំនួនបួន៖ ធនធានមានកំណត់ ប្រសិទ្ធភាពការងារផ្ទៃក្នុង ប្រសិទ្ធភាពការងារខាងក្រៅ និងសមភាពសង្គម។ ការបង្រៀនរបស់គ្រូទៀតសោតក៏ពុំសូវល្អ ខណៈដែលប្រាក់ខែទាប និងឈានទៅបោះបង់អាជីពបង្រៀនថែមទៀត (Lim, 1999)។ ជាមួយគ្នានេះ Lim ក៏បានបន្ថែមទៀតថានយោបាយមានអន្តរាគមន៍ចូលក្នុងការសាកលវិទ្យាល័យ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដែលធ្វើឱ្យគ្រឹះស្ថានបណ្ដុះបណ្ដាលមិនអាចអនុវត្តពេញលេញនូវវិជ្ជាជីវៈរបស់ខ្លួន។ កង្វះហេដ្ឋារចនាសម្ព័ន្ធ សម្ភារពិសោធន៍ កុំព្យូទ័រនិងកម្មវិធីផ្នែកទន់ សម្ភារសិក្សា (សៀវភៅសិក្សាគោល និងទស្សនាវដ្ដីស្រាវជ្រាវ) គុណវុឌ្ឍិគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្រាវជ្រាវ (World Bank, 2000)។ គ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍជួបបញ្ហាប្រឈមរួមមាន៖ ការចូលរៀន ប្រសិទ្ធភាព សមធម៌ ហិរញ្ញវត្ថុ គុណភាព និងការងារពាក់ព័ន្ធ (World Bank, 2017)។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពឧត្តមសិក្សា និងលើកកម្ពស់សេវានិស្សិត ការស្រាវជ្រាវមួយចំនួនត្រូវបានលើកឡើង។ ការកែសម្រួលកម្មវិធីសិក្សា វិធីសាស្ត្របង្រៀនថ្មី គួរតែធ្វើឡើង ដើម្បីបង្កើនសមត្ថភាពគិតស៊ីជម្រៅ និងជំនាញក្នុងការគិតក្នុងការសិក្សានៅសាកលវិទ្យាល័យ។ បន្ថែមពីនេះ ការគាំទ្រលើការជួយអភិវឌ្ឍសមត្ថភាពបុគ្គលិកក៏ជាចំណុចសំខាន់ផងដែរ (UNESCO, 1998)។ ចំណែក Rowan et al. (2010) ក៏បានលើកឡើងថាការបែងចែកការលើកកម្ពស់គុណភាពឧត្តមសិក្សាមានចំណុចចំនួនបួនត្រូវពិចារណារួមមាន៖ ជំនួយហិរញ្ញវត្ថុ (អាហារូបករណ៍និងកម្ចីលើការសិក្សា) គាំទ្រលើការរៀននិងបង្រៀន (វិធីសាស្ត្របង្រៀន និងការបង្រៀនបំប៉ន) អភិវឌ្ឍសមត្ថភាពនិងប្រឹក្សាយោបល់ (តម្រង់ទិស និងប្រឹក្សាយោបល់) និងការគាំទ្រពីគ្រឹះស្ថានឧត្តមសិក្សា (ការឆ្លើយតបបានទាន់ពេល និងការស្នាក់នៅជាដើម)។ គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំសកម្មភាពគាំទ្រដល់និស្សិតពីរទម្រង់ រួមមានការគាំទ្រផ្នែកសិក្សា និងមិនមែនសិក្សា។ ផ្នែកសិក្សាសំដៅដល់ការរៀបចំកម្មវិធី និងសកម្មភាពជួយនិស្សិតឆ្នាំទី១ ឱ្យទទួលបានមធ្យមភាគប្រចាំឆ្នាំ (GPA) ខ្ពស់។ តាមការស្រាវជ្រាវបង្ហាញថា និស្សិតដែលទទួលបានមធ្យមភាគប្រចាំឆមាស និងប្រចាំឆ្នាំច្រើន ភាគរយនៃ

ការបោះបង់ទាប (Tinto, 1975)។ សកម្មភាពមិនមែនសិក្សា រួមមានសកម្មភាពបង្កើនទំនុកចិត្តលើការសិក្សា ការគាំទ្រ និងចូលរួមពីសង្គម និងការលើកទឹកចិត្ត ដែលទាំងអស់នេះជួយលើផ្នែកសិក្សារបស់និស្សិតយ៉ាងសំខាន់ (Lotkowski et al., 2004)។

ទន្ទឹមនេះ ការសិក្សារបស់ Heng (2013)បានបង្ហាញថា ការគាំទ្រនិងមតិឆ្លើយតបរបស់គ្រឹះស្ថានទៅកាន់និស្សិតគឺជាកត្តាសំខាន់ជាងគេ ដែលមានផលជះវិជ្ជមានខ្លាំងជាងគេទៅលើលទ្ធផលសិក្សារបស់និស្សិត។ តួយ៉ាង Dickson et al. (2024) បានរកឃើញថាការចូលរួមពីភាគីពាក់ព័ន្ធផ្តល់នូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងគ្រឹះស្ថានលើការផ្តល់សេវានិស្សិត។ ការគ្រប់គ្រងមានតែរដ្ឋ និងគ្រឹះស្ថានឧត្តមសិក្សាពុំបានផ្តល់ប្រសិទ្ធភាពសេវានោះទេ ដោយសារកង្វះថវិកា កង្វះទំនុកចិត្តរវាងរដ្ឋនិងគ្រឹះស្ថាន ហើយមិនអាចទាក់ទងវិស័យឯកជនមកចូលរួមបាន (Habtom, 2020)។ ស្របគ្នានេះ Mitchell et al. (2020) បានបង្ហាញថាទំនាក់ទំនងរវាងគ្រឹះស្ថាន និងភាគីពាក់ព័ន្ធដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីលើកកម្ពស់គុណភាពសេវានិស្សិត។ កិច្ចសហការនេះគឺជាមធ្យោបាយឆ្លើយតបទៅនឹងតម្រូវការផ្សេងៗរបស់និស្សិត និងសម្របសម្រួលដល់ភាពជោគជ័យលើការសិក្សារបស់គាត់។ បន្ថែមពីនេះ Oketch (2016) បានរំលេចថា ការវិនិយោគរបស់ធនាគារពិភពលោកក្នុងប្រទេសកំពុងអភិវឌ្ឍជួយឱ្យប្រសើរឡើងលើហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះបណ្តាល មន្ត្រី ដើម្បីពង្រឹងសេវាផ្តល់ជូននិស្សិត។ ការវិនិយោគទាំងនេះជាពិសេសនៅប្រទេសកម្ពុជាការអភិវឌ្ឍបានផ្តល់នូវបរិស្ថានសិក្សាល្អ លទ្ធភាពចូលសិក្សាខ្ពស់ និងរីករាយក្នុងជីវិតសិក្សា។ ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលដើរតួសំខាន់ក្នុងការជំរុញភាពជាដៃគូ លើកកម្ពស់ភាពជោគជ័យការលើសិក្សារបស់និស្សិត (Dickson et al., 2024)។

ដូច្នេះ ការស្រាវជ្រាវនេះមានគោលបំណងសិក្សាអំពីសេវានិស្សិតរបស់គ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសកម្ពុជា។ ការសិក្សានេះផ្តោតលើការអនុវត្ត និងអនុសាសន៍ពង្រឹងគុណភាពសេវានិស្សិតតាមគ្រឹះស្ថានឧត្តមសិក្សា។

ដើម្បីសម្រេចគោលបំណងខាងលើ សំណួរស្រាវជ្រាវចំនួនពីរត្រូវបានលើកឡើង៖

១.តើការអនុវត្តសេវានិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាមានលក្ខណៈដូចម្តេចខ្លះ?

២.តើសេវានិស្សិតល្អមានលក្ខណសម្បត្តិដូចម្តេចខ្លះ?

## វិធីសាស្ត្រស្រាវជ្រាវ

### នីតិវិធីនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណង និងសំណួរស្រាវជ្រាវឱ្យទទួលបានទិន្នន័យលម្អិត ជាក់ស្តែង និងមានគុណភាព ការស្រាវជ្រាវបែបគុណវិស័យត្រូវបានជ្រើសរើស។ ការស្រាវជ្រាវបែបគុណវិស័យពិតជាមានលក្ខណសម្បត្តិ និងមានសារៈប្រយោជន៍គ្រប់គ្រាន់ ដើម្បីឱ្យអ្នកស្រាវជ្រាវទទួលបានព័ត៌មានកាន់តែស៊ីជម្រៅពីភាគីពាក់ព័ន្ធទៅលើសេវានិស្សិតក្នុងគ្រឹះស្ថានឧត្តមសិក្សា និងរបៀបដែលគ្រឹះស្ថានឧត្តមសិក្សាផ្តល់ជូននិស្សិត។ ជាក់ស្តែង Creswell (2012) ក៏បានលើកឡើងថា ការស្រាវជ្រាបែបគុណវិស័យជួយឱ្យអ្នកស្រាវជ្រាវមានលទ្ធភាពក្នុងការស្វែងរកគោលគំនិត និងព័ត៌មានកាន់តែលម្អិតពីសំណាក ដោយទទួលបានខ្លឹមសារ និងសកម្មភាពទាក់ទងពីពួកគាត់ផ្ទាល់តែម្តង។ ស្របគ្នានេះ

ផងដែរ Patton (2002) ក៏បានលើកឡើងថាការស្រាវជ្រាវបែបគុណវិស័យជួយឱ្យអ្នកស្រាវជ្រាវងាយស្រួលក្នុងការធ្វើការបញ្ជាក់ និងបែងចែកគោលគំនិតណាមួយដែលសំខាន់ៗជាងគេបំផុតដោយលម្អិត។

### ទីកន្លែងស្រាវជ្រាវ និងសំណាកគំរូ

ការសិក្សាស្រាវជ្រាវនេះជ្រើសរើសយកគ្រឹះស្ថានឧត្តមសិក្សា ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានទីតាំងក្នុងរាជធានីភ្នំពេញ។ ការជ្រើសរើសគ្រឹះស្ថានក្នុងរាជធានីភ្នំពេញដោយឈរលើមូលដ្ឋានជាទីកន្លែងបណ្តុំនៅគ្រឹះស្ថានឧត្តមសិក្សារដ្ឋដែលមានចំនួននិស្សិតចូលសិក្សាច្រើនជាងគេ បើប្រៀបធៀបជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាតាមខេត្ត។ គ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួនបីត្រូវបានជ្រើសរើស ដោយជាគ្រឹះស្ថានសិក្សាដែលមាននិស្សិតចូលរៀនច្រើនជាងគេក្នុងឆ្នាំសិក្សា២០២២-២០២៣។ ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា អ្នកចូលរួមស្រាវជ្រាវជាថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សាអាចជាសាកលវិទ្យាធិការ ឬថ្នាក់ដឹកនាំទទួលបន្ទុកសេវានិស្សិតចំនួន១នាក់ ថ្នាក់ដឹកនាំផ្នែកធានាគុណភាព ឬថ្នាក់ដឹកនាំផ្នែកកិច្ចការនិស្សិតចំនួន១នាក់ និងនិស្សិតចំនួន ៨ នាក់។ សរុបបទសម្ភាសដោយផ្ទាល់ជាមួយថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សា និងអ្នកពាក់ព័ន្ធចំនួន ៨នាក់ និងបទសម្ភាសជាក្រុមជាមួយនិស្សិតចំនួន ២៤នាក់។ សមាសភាពចំនួនបីត្រូវបានជ្រើសរើសគឺគ្រឹះស្ថានឧត្តមសិក្សា (ថ្នាក់ដឹកនាំ អ្នកផ្តល់សេវា និងនិស្សិត) ថ្នាក់ដឹកនាំជាន់ខ្ពស់នៃ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា និងអគ្គនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា។

តារាងទី៣៖ *ព័ត៌មានប្រជាសាស្ត្រអ្នកចូលរួមក្នុងការស្រាវជ្រាវ*

| សមាសភាព | ភេទ | តួនាទី | ចំនួន | សម្ភាស | កូដ |
|---|---|---|---|---|---|
| ក្រសួងអប់រំ យុវជន និងកីឡា | ប្រុស | អគ្គលេខាធិការដ្ឋាន | 1 | ម្នាក់ទល់ម្នាក់ | R1 |
| ក្រសួងអប់រំ យុវជន និងកីឡា | ប្រុស | អគ្គនាយដ្ឋាន | 1 | ម្នាក់ទល់ម្នាក់ | R2 |
| គ្រឹះស្ថាននិស្សិតច្រើនទី១ | ប្រុស | ថ្នាក់ដឹកនាំគ្រឹះស្ថាន | 1 | ម្នាក់ទល់ម្នាក់ | R3 |
| គ្រឹះស្ថាននិស្សិតច្រើនទី២ | ប្រុស | ថ្នាក់ដឹកនាំគ្រឹះស្ថាន | 1 | ម្នាក់ទល់ម្នាក់ | R4 |
| គ្រឹះស្ថាននិស្សិតច្រើនទី៣ | ប្រុស | ថ្នាក់ដឹកនាំគ្រឹះស្ថាន | 1 | ម្នាក់ទល់ម្នាក់ | R5 |
| មន្ត្រីផ្នែកសេវានិស្សិតនៃគ្រឹះស្ថានទី១ | ប្រុស | ប្រធានការិយាល័យ | 1 | ម្នាក់ទល់ម្នាក់ | R6 |
| មន្ត្រីផ្នែកសេវានិស្សិតនៃគ្រឹះស្ថានទី២ | ប្រុស | ប្រធានការិយាល័យ | 1 | ម្នាក់ទល់ម្នាក់ | R7 |
| មន្ត្រីផ្នែកសេវានិស្សិតនៃគ្រឹះស្ថានទី៣ | ស្រី | ប្រធានការិយាល័យ | 1 | ម្នាក់ទល់ម្នាក់ | R8 |
| ក្រុមនិស្សិតនៃគ្រឹះស្ថានទី១ | ចម្រុះ | និស្សិត | 8 | ជាក្រុម | R9 |
| ក្រុមនិស្សិតនៃគ្រឹះស្ថានទី២ | ចម្រុះ | និស្សិត | 8 | ជាក្រុម | R10 |
| ក្រុមនិស្សិតនៃគ្រឹះស្ថានទី៣ | ចម្រុះ | និស្សិត | 8 | ជាក្រុម | R11 |

## ឧបករណ៍ស្រាវជ្រាវ

ការស្រាវស្រាវនេះប្រើប្រាស់ការសម្ភាសពាក់កណ្ដាលគ្រោងទុក ដោយមានសំណួរគ្រោងទុកមួយចំនួន និងការសួរផ្ទាល់ភ្លាមៗ កំឡុងពេលសម្ភាស ដើម្បីទទួលទិន្នន័យកាន់តែស៊ីជម្រៅ និងជាក់លាក់ពីអ្នកចូលរួម។ ការធ្វើបទសម្ភាសជាឧបករណ៍ដ៏ចាំបាច់បំផុត និងមិនអាចខ្វះបានក្នុងការប្រមូលទិន្នន័យឱ្យឆ្លើយតបទៅនឹងគោលបំណងស្រាវជ្រាវខាងលើ។តួយ៉ាង Cohen et al. (2007) បានបង្ហាញថាការសម្ភាសមានគោលបំណងច្រើនប្រភេទ ដូចជាវាយតម្លៃ សម្រិតសម្រាំងតេស្ត និងអភិវឌ្ឍសម្មតិកម្ម និងប្រមូលទិន្នន័យ។ ការស្រាវជ្រាវនេះគឺសម្ភាសម្នាក់ទល់ម្នាក់ជាមួយថ្នាក់ដឹកនាំ និងអ្នកផ្ដល់ សេវានិស្សិត ខណៈដែលការសម្ភាសជាក្រុមធ្វើឡើងចំពោះនិស្សិត។ បទសម្ភាសម្នាក់ទល់ម្នាក់ គឺដើម្បីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ជាពិសេសទទួលបទពិសោធ និងមតិយោបល់ពីសំណាកគំរូគោលដៅ ព្រមទាំងធ្វើឱ្យទិន្នន័យកាន់តែសំបូរបែប និងក្បោះក្បាយ។ ទិន្នន័យទទួលបានក៏មានជាការស្រង់សម្ដី ដែលធ្វើឱ្យខ្លឹមសារកាន់តែច្បាស់លាស់ (Patton, 2002)។ ស្របគ្នានេះ Cohen et al. (2007)ក៏បានបង្ហាញថាបទសម្ភាសជាក្រុមផ្ដល់លទ្ធភាពឱ្យអ្នកចូលរួមក្នុងការសិក្សានេះផ្ដល់ព័ត៌មាបានច្រើន និងបំពេញបន្ថែមគ្នាទៅវិញទៅមក។

កម្រងសំណួរសម្រាប់បទសម្ភាសអ្នកចូលរួមការស្រាវជ្រាវនេះចែកចេញជាពីរផ្នែកៈ ផ្នែកទី១ ផ្ដោតលើរបៀបនិងស្ថានភាពនៃការផ្ដល់សេវានិស្សិត ដែលមានពីរសំណួរ និងផ្នែកទី២ ផ្ដោតលើយន្តការក្នុងការពង្រឹងគុណភាពសេវានិស្សិត ដោយមានសំណួរចំនួនបី។ សំណួរទាំងនេះបានកែសម្រួលពី Johnson et al. (2022) និងដកស្រង់ចេញពីការស្រាវជ្រាវរបស់ Mulaudzi (2023) ។

## ដំណើរការប្រមូលទិន្នន័យ

ស្របតាមក្រមសីលធម៌ និងនីតិវិធីរដ្ឋបាល អ្នកស្រាវជ្រាវបានរៀបចំលិខិតស្នើសុំធ្វើបទសម្ភាសជាមួយគ្រឹះស្ថានឧត្ដមសិក្សាចំនួនប្រាំមួយ និងភាគីពាក់ព័ន្ធ ដោយភ្ជាប់ជាមួយនឹងកម្រងសំណួរសម្ភាស។ បន្ទាប់ពីទទួលបានការអនុញ្ញាតពីគ្រឹះស្ថាន និងអ្នកពាក់ព័ន្ធ អ្នកស្រាវជ្រាវបានធ្វើការណាត់ជួបសម្ភាសទៅតាមពេលវេលាសមស្របរបស់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។ ការណាត់ជួបធ្វើតាមតាមប្រព័ន្ធបណ្ដាញសង្គម និងតាមការទូរសព្ទអាស្រ័យលើភាពងាយស្រួលជាមួយអ្នកចូលរួមការស្រាវជ្រាវ។ ចំពោះការជួបផ្ដល់បទសម្ភាសន៍គឺមានទីតាំងផ្សេងៗគ្នា អាស្រ័យលើការជ្រើសរើសរបស់អ្នកចូលរួមស្រាវជ្រាវ។ មុនចាប់ផ្ដើមបទសម្ភាស អ្នកស្រាវជ្រាវបានបង្ហាញពីគោលបំណងនៃការស្រាវជ្រាវ និងការរក្សាការសម្ងាត់ចំពោះលទ្ធផលទទួលបានពីអ្នកចូលរួម។ អ្នកចូលរួមមានសិទ្ធិ និងផ្ដល់យោបល់លើចំណុចណាមួយ ឬបញ្ឈប់ការឆ្លើយត្រឹមចំណុចណាមួយបាន។ បទសម្ភាសដោយផ្ទាល់ម្នាក់ទល់ម្នាក់ប្រើប្រាស់ពេលវេលាយ៉ាងតិចបំផុត ៤៥នាទីក្នុងម្នាក់។ មុននឹងចាប់ផ្ដើមសម្ភាស អ្នកស្រាវជ្រាវបានអានកិច្ចព្រមព្រៀងសម្ភាស ដោយភ្ជាប់ជាមួយនឹងគោលបំណង និងធន្ទានុសិទ្ធិរបស់អ្នកចូលរួម។ បន្ថែមពីនេះ ការម្ភាស និងការថតសំឡេងនីមួយអាចរៀបចំឡើង លុះត្រាណាអ្នកចូលរួមបានចុះហត្ថលេខាព្រមព្រៀងជាមុន។ ខណៈដែលបទសម្ភាសជាក្រុមជាមួយនិស្សិតប្រើប្រាស់ពេលវេលាយ៉ាងតិចបំផុត៦០នាទី ដោយមានដំណើរការប្រព្រឹត្តទៅ ជាមួយលក្ខខណ្ឌដូចសម្ភាសម្នាក់ទល់ម្នាក់ដែរ។ ការសម្ភាសជាក្រុមនិស្សិតអាចជ្រើសរើសទីតាំងណាមួយដែលពួកគាត់ពេញចិត្ត ទទួលអារម្មណ៍កក់ក្ដៅ និងផ្ដល់ព័ត៌មានស៊ីជម្រៅ។

## ការវិភាគទិន្នន័យ

អ្នកស្រាវជ្រាវបានអានរាល់ចម្លើយដោយយកចិត្តទុកដាក់ ដើម្បីកត់ចំណាំ (ប្រើលេខសម្គាល់ចង្កោមសកម្មភាព) នូវគំនិតសំខាន់ៗ ដែលអ្នកចូលរួមក្នុងការសម្ភាសបានឆ្លើយ។ តួយ៉ាង Braun and Clarke (2006) អ្នកស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យទទួលបានពីអ្នកចូលរួមការស្រាវជ្រាវទៅតាមចង្កោមសកម្មភាពនីមួយៗ ដោយប្រើប្រាស់វិធីសម្ភាសកេប្រធានបទគោល។ បន្ថែមពីនេះ អ្នកស្រាវជ្រាវបានរក្សាអនុសាសន៍របស់អ្នកធ្វើបទសម្ភាស ដើម្បីបញ្ជាក់បន្ថែម។ បន្ថែមពីនេះ Creswell (2012) ការវិភាគទិន្នន័យដោយខ្លួនឯង ធ្វើឱ្យអ្នកស្រាវជ្រាវអានគំនិតរបស់សំណាក ធ្វើការគូសចំណាំ និងបែងចែកគំនិតសំខាន់តាមផ្នែកនីមួយៗ។ គាត់បានបន្ថែមទៀតថា ការវិភាគទិន្នន័យបែបនេះកាលពីមុន អ្នកស្រាវជ្រាវបាន ប្រើប្រាស់ពណ៌សម្រាប់រៀបចំគោលគំនិតក្នុងទិន្នន័យធំ និងសរសេរជាផ្នែកៗ។ អ្នកស្រាវជ្រាវបានជ្រើសរើសនូវមូលន័យទិន្នន័យយ៉ាងម៉ត់ចត់បំផុត បញ្ចូលទៅក្នុងគោលគំនិតទទួលបានពីការរំលឹកទ្រឹស្តី និងចម្រាញ់យកទិន្នន័យនោះឱ្យក្លាយជាលទ្ធផលស្រាវជ្រាវ ដោយប្រឹក្សាជាមួយអ្នកនិពន្ធដែលមានបទពិសោធលើការងារប្រមូលទិន្នន័យបែបគុណវិស័យជាច្រើនឆ្នាំ និងយកទៅផ្ទៀតផ្ទាត់ជាមួយអ្នកស្រាវជ្រាវផ្សេងទៀត។ ការវិភាគទិន្នន័យត្រូវបានធ្វើឡើងដោយអ្នកនិពន្ធទី១ ក្រោមការណែនាំ ចង្អុលបង្ហាញ និងចែករំលែកពីសហអ្នកនិពន្ធមានបទពិសោធក្នុងការប្រមូលទិន្នន័យបែបគុណវិស័យ។

## លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

### ការអនុវត្តសេវានិស្សិត

#### *ស្ថានភាពទូទៅ*

ការដាក់ចេញនូវយុទ្ធសាស្ត្រក្នុងការបង្កើតមូលធនមនុស្សសម្រាប់ប្រទេសជាតិ គឺជាបេសកកម្មដ៏មានសារសំខាន់ក្នុងការឈានទៅនាំសង្គម និងសេដ្ឋកិច្ចកម្ពុជាមានភាពធន់ រឹងមាំ និងឈានទៅសម្រេចចក្ខុវិស័យរបស់ខ្លួននៅឆ្នាំ២០៥០ (RGC, 2023)។ ការបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សា គឺជាកម្រិតបណ្តុះបណ្តាលកម្រិតខ្ពស់របស់កម្ពុជា ដើម្បីផលិតមូលធនមនុស្សប្រកបដោយគុណភាព ឆ្លើយតបទៅនឹងតម្រូវការសង្គម និងទីផ្សារការងារ។ គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាបានកើតឡើង រលត់ទៅវិញ និងចាប់ផ្តើមសាជាថ្មីម្តងទៀត ជាច្រើនដំណាក់កាល ក្រោមស្ថានភាពសង្គមពុំមានស្ថេរភាព និងសង្គ្រាមស៊ីវិលជាដើម (ACC, 2011) ។ ជាក់ស្តែង ទើបនៅក្រោយឆ្នាំ១៩៧៩ គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាបានបើកទ្វាឡើងវិញម្តងទៀត ក្រោយអាក់ខាននៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ការចាប់ផ្តើមម្តងនេះ គឺជាការចាប់ផ្តើមដ៏លំបាកមួយ ឬអាចនិយាយបានថា ជាការចាប់ផ្តើមពីសូន្យតែម្តង គឺក្រោយពីប្រព័ន្ធអប់រំ និងគ្រឹះស្ថាន ឧត្តមសិក្សាបានបិទទ្វាចោលទាំងស្រុងក្នុងសម័យសោនាដកម្មនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ដែលដំណាក់កាលនេះ មិនត្រឹមតែមិនបានបន្តការអប់រំ និងអនុវត្តការពង្រឹងការអប់រំនោះឡើយ គឺប្រព័ន្ធអប់រំជាតិទាំងមូលត្រូវបានបំផ្លាញចោលទាំងស្រុង។ វត្តមាននៃគ្រឹះស្ថានឧត្តមសិក្សាក្រោយឆ្នាំ១៩៧៩ គឺជាការចាប់ផ្តើមជ្រើសរើសគ្រូបង្រៀនដែលនៅសេសសល់ ទីតាំងដែលត្រូវបំផ្លាញ និងបោះបង់ចោល។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្តីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោមៈ

សាកលវិទ្យាល័យរដ្ឋមួយចំនួនដណ្តើមគ្នាថា ជាសាកលវិទ្យាល័យចាស់ជាងគេ ដោយកំណត់យកឆ្នាំបង្កើត ១៩៥០ ឬ១៩៦០ ឬ១៩៧០ ក្នុងគោលបំណងខិតខំលើកតម្កើងទាមទារភាពចាស់ជាងគេ និងបទពិសោធ។ តែតាមការពិត គ្រឹះស្ថានឧត្តមសិក្សាទាំងនោះកើតឡើងក្នុងពេលប្រហាក់ប្រហែលគ្នាគឺនៅទសវត្សឆ្នាំ១៩៨០ ដោយចេញពីសូន្យតែម្តង ព្រោះទាំងគ្រូ ទាំងអគារសិក្សា និងសិស្សគឺដើររើស បង្រៀន និងចូលបង្រៀនតាមរយៈទស្សន "អ្នករៀនច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ"។ R2

នៅឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យបង្កើតអង្គភាពថ្នាក់ជាតិមួយ ដើម្បីមានមុខងារ និងភារកិច្ចពិនិត្យ និងវាយតម្លៃគុណភាពគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេស។ ស្តង់ដាអប្បរមាវាយតម្លៃគុណភាពអប់រំកម្រិតឧត្តមសិក្សាត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា (RGC, 2022) ឬហៅកាត់ថា គទក ឬ ACC។ ក្នុងចំណោមស្តង់ដាទាំងប្រាំបួន ដែលរួមមាន ចក្ខុវិស័យ បេសកកម្ម និងគោលដៅ អភិបាលកិច្ចនិងការគ្រប់គ្រង បុគ្គលិកអប់រំ កម្មវិធីសិក្សា ធនធានសិក្សា ធនធានរូបវន្ត ធនធានហិរញ្ញវត្ថុ និងការធានាគុណភាពផ្ទៃក្នុង ខណៈដែលសេវានិស្សិតត្រូវបានកំណត់ជាស្តង់ដាទី៥ ក្នុងការវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា។ សេវានិស្សិតជាផ្នែកមួយសំខាន់ក្នុងការផ្តល់ការគាំទ្រ និងគាំពារនិស្សិតឱ្យទទួលបាននូវទំនុកចិត្ត ផាសុកភាព និងជំនឿមុតមាំក្នុងការសិក្សា និងឈានទៅសម្រេចគោលដៅសិក្សាឧត្តមសិក្សាប្រកបដោយភាពជោគជ័យ។ និស្សិតត្រូវបានកំណត់ជាតួអង្គដែលមានចំនួនច្រើនជាងគេក្នុងគ្រឹះស្ថាន និងជាអតិថិជនដ៏សំខាន់ផងដែរ។ គ្រឹះស្ថានផ្តល់សេវាគាំទ្រ ផ្តល់ទំនុកចិត្តកាន់តែល្អ និងគុណភាព គ្រឹះស្ថានទទួលបានការចាប់អារម្មណ៍ និងក្លាយជាគោលដៅសំខាន់របស់និស្សិត។ គ្រឹះស្ថានឧត្តមសិក្សាបានទទួលស្គាល់ថា ភាពជោគជ័យនៃការសិក្សាគឺផ្អែកលើនិស្សិតមានសុខភាពល្អ ការលើកទឹកចិត្ត និងគុណភាពការសិក្សា (UNESCO, 2009)។ ការសិក្សាស្របតាមកម្មវិធីសិក្សាពុំទាន់បានផ្តល់លទ្ធភាពគ្រប់គ្រាន់សម្រាប់និស្សិតក្នុងការបង្កើនសមត្ថភាពជំនាញខ្ពស់ ឥរិយាបថល្អ និងជំនាញទន់ល្អប្រសើរឡើយ គឺពិតជាទាមទារឱ្យនិស្សិតចូលរួមសកម្មភាពបន្ថែមក្រៅពីកម្មវិធីសិក្សា តាមរយៈការរៀបចំសកម្មភាពផ្សេងៗ និងឈានទៅប្រែក្លាយខ្លួនជាពលរដ្ឋសកលពេញលេញ។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្តីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

> សេវានិស្សិតមានសារសំខាន់ណាស់ ដើម្បីជួយនិស្សិត ព្រោះនិស្សិតពុំមានកម្រិតចំណេះដឹង និងការត្រៀមខ្លួនដូចគ្នានោះទេ គឺត្រូវការការជួយបន្ថែម។ និស្សិតសំខាន់ ព្រោះគាត់ជាអតិថិជនរបស់សាលាផង និងជាអតិថិជនរបស់សហគ្រាសផងដែរ។ ឥរិយាបថមិនបានបង្ហាញទាំងស្រុងនៅក្នុងសៀវភៅមេរៀននោះទេ តែនិស្សិតអាចកែលម្អបានតាមរយៈការចូលរួមសកម្មភាពសង្គមផ្សេងៗ ដែលសកម្មភាពទាំងនេះជួយឱ្យនិស្សិតចេះធ្វើការជាមួយគ្នា និងមានទំនាក់ទំនងជាមួយសង្គម។ R1

លទ្ធផលនេះដូចនឹងការលើកឡើងរបស់ Chodaha (2009) ដែលបានលើកឡើងថាការផ្តល់ឱកាស និងរៀបចំកម្មវិធីឱ្យនិស្សិតបានរៀន សូត្រចំណេះដឹងថ្មីៗ ក្រៅពីថ្នាក់រៀនក៏នៅមានដែនកំណត់នៅឡើយ។ ការភ្ជាប់និស្សិតទៅនឹងសហគមន៍តាមរយៈការងារស្ម័គ្រចិត្ត ការចុះអនុវត្ត និងសិក្សាសហគមន៍។ និស្សិតនឹងបានស្វែងយល់បន្ថែមពីបញ្ហា និងតម្រូវការរបស់សហគមន៍។ ស្របគ្នានឹងការលើកឡើងរបស់ Reeves and Hare (2009) បានលើក

ឡើងថាសកម្មភាពជាមួយសហគមន៍ជួយពង្រឹងសមត្ថភាពរបស់និស្សិតបន្ថែមទៀត ក្រៅពីការសិក្សាក្នុងថ្នាក់រៀន ។ សម្រង់សម្ដីរបស់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងដូចគ្នាផងដែរ។

> សេវានិស្សិតជួយឱ្យនិស្សិតមានឯករាជ្យភាព ខណៈជីវិតនៅវិទ្យាល័យគាត់ទទួលបានការគ្រប់គ្រងផ្ទាល់ពីឳពុកម្ដាយ។ ពេលចូលមកដល់សាកលវិទ្យាល័យ ពិតជាត្រូវការខ្លាំងណាស់នូវសេវាកម្មរបស់សាកលវិទ្យាល័យ។ បន្ថែមពីនេះ ផ្អែកលើអនុក្រឹត្យ លេខ ៥៤ ស្ដីពីលក្ខណវិនិច្ឆ័យបង្កើតសាកលវិទ្យាល័យបានបញ្ជាក់យ៉ាងច្បាស់ថា គោលបំណងនៃការបង្កើតសាកលវិទ្យាល័យ គឺដើម្បីរួមចំណែកលើកស្ទួយវប្បធម៌ជាតិ។ ក្នុងន័យនេះការបង្កើតសកម្មភាពចូលរួមសកម្មភាពប្រពៃណី និងវប្បធម៌ជាដើម ក្រៅពីកម្មវិធីសិក្សាជារឿងសំខាន់ណាស់។ R2)

អត្រានិស្សិតបង់ថ្លៃសិក្សាច្រើនក្នុងគ្រឹះស្ថានជួយឱ្យគ្រឹះស្ថានទទួលបានចំណូលច្រើនផងដែរ ដើម្បីបង្កើនគុណភាពលើការងារអប់រំ បង្កើនសកម្មភាពជួយនិស្សិតកាន់តែសម្បូរបែប និងឆ្លើយតបទៅនឹងតម្រូវការ ខណៈការទទួលថវិកាតែមួយច្រក និងមានចំនួនតិចមិនអាចជួយទ្រទ្រង់គ្រឹះស្ថាន ធានាពីគុណភាព និងការអភិវឌ្ឍរបស់គ្រឹះស្ថានឧត្ដមសិក្សាបានល្អប្រសើរខ្លាំងនោះទេ។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្ដីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

> សាកលវិទ្យាល័យផ្ដល់សេវាល្អ និស្សិតចូលរៀនច្រើន បង្កើនប្រាក់ចំណូលដល់គ្រឹះស្ថាន ថវិកានេះជួយដល់គុណភាពគ្រឹះស្ថាន។ នៅប្រទេសអភិវឌ្ឍប្រាក់ចំណូលគ្រឹះស្ថានគឺមិនពឹងផ្អែកទាំងស្រុងលើថវិកាឧបត្ថម្ភពីរដ្ឋនោះទេ។ ថវិកាមកពីផ្នែកក្រៅថវិការដ្ឋ គឺជាប្រភពថវិកាធំជាងគេរបស់សាកលវិទ្យាល័យ (Non-Government Funding)។ ដូចនេះ សាកលវិទ្យាល័យមិនមែនបណ្ដុះបណ្ដាលចប់តាមកម្មវិធី តែមិនទទួលបានចំណេះដឹង និងអត់ការងារធ្វើនោះទេ។ និស្សិតគឺត្រូវធ្វើការស្របតាមជំនាញ និងប្រាក់ខែសមរម្យ ស្របតាមទីផ្សារការងារ ព្រោះបើប្រាក់ខែស្មើនឹងកម្មករអត់ជំនាញ ចាំបាច់រៀនដល់១២ឆ្នាំ បូក៤ បូក៣ និង២ ធ្វើអ្វីទៀត។ R2

សេវានិស្សិតដើរតួនាទីសំខាន់ក្នុងការជួយនិស្សិត បង្កើនគុណភាពអប់រំ និងលើកកិត្យានុភាពរបស់គ្រឹះស្ថានឧត្ដមសិក្សាយ៉ាងមានប្រសិទ្ធភាព។ តួយ៉ាង Dhillon et al.(2008) បានបញ្ជាក់ថាការរៀបចំប្រព័ន្ធគាំទ្រ និងជួយនិស្សិតផ្ដល់អត្ថប្រយោជន៍ទាំងនិស្សិតនិងគ្រឹះស្ថានឧត្ដមសិក្សាផងដែរ។ តែការអនុវត្តសេវានិស្សិតនៅក្នុងគ្រឹះស្ថានឧត្ដមសិក្សារដ្ឋក្នុងប្រទេសកម្ពុជាពុំបានល្អគ្រប់ជ្រុងជ្រោយនោះឡើយ គឺមានន័យថាគ្រឹះស្ថាននីមួយៗបានអនុវត្តសេវានិស្សិតទៅតាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួន ហើយការរៀបចំនេះទៀតសោតពុំបានត្រឹមត្រូវ និងឆ្លើយតបទៅនឹងតម្រូវការនិស្សិត។ សកម្មភាពទាំងនេះ ធ្វើឱ្យយើងដឹងថា ការអនុវត្តសេវានិស្សិតនៅតាមគ្រឹះស្ថានឧត្ដមសិក្សានៅពុំទាន់បានពេញលេញ គ្រប់ជ្រុងជ្រោយ និងគុណភាពខ្ពស់ ឆ្លើយតបទៅនឹងបេសកកម្ម និងស្តង់ដាពិនិត្យ វាយតម្លៃគុណភាពអប់រំនៅឡើយ។ គ្រឹះស្ថានឧត្ដមសិក្សាមួយចំនួនរៀបចំសេវានិស្សិត គឺមុនពេល និងកំឡុងពេលនៃការចុះពិនិត្យនិងវាយតម្លៃរបស់អង្គភាពមានសមត្ថកិច្ចប៉ុណ្ណោះ។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្ដីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

ជាទូទៅសាកលវិទ្យាល័យមិនទាន់យកចិត្តទុកដាក់នៅឡើយ ព្រោះការរៀបចំនេះមានលក្ខណរាយ ប៉ាយនៅឡើយ។ មហាវិទ្យាល័យធ្វើ ជួយត្រឹមមហាវិទ្យាល័យ ឬដេប៉ាតឺម៉ង់ធ្វើជាដេប៉ាតឺម៉ង់។ R1

បន្ថែមពីនេះ ការផ្តល់សេវានិស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សាពុំមែនកើតចេញពីឆន្ទៈពិតប្រាកដរបស់ថ្នាក់ដឹកនាំគ្រឹះស្ថាននោះទេ គឺជាការរៀបចំ ដើម្បីប្រយោជន៍ទាញប្រជាប្រិយភាពពីនិស្សិត។ ដូចគ្នាទៅនឹងការលើកឡើងរបស់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

ការផ្តល់សេវានិស្សិតរបស់គ្រឹះស្ថានគឺហុតទឹកសម្លឹងកាក គឺមានន័យថា ការធ្វើសកម្មភាពទាំងនេះមិនកើតឡើងដោយភាពបរិសុទ្ធនោះទេ។ គ្រឹះស្ថានប្រើប្រាស់រូបភាព ដើម្បីទាញចំណេញពីនិស្សិត។ R2

**ថ្នាក់ក្រសួងអាណាព្យាបាលបច្ចេកទេស**

***យន្តការវាយតម្លៃគុណភាព***

ការវាយតម្លៃគុណភាពនៅឧត្តមសិក្សាបានបែងចែកជាពីរ៖ ការវាយតម្លៃផ្ទៃក្នុងរៀបចំដោយគ្រឹះស្ថានឧត្តមសិក្សា និងការវាយតម្លៃផ្លូវការពីខាងក្រៅ គឺស្នើមកគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជា (Royal Degree, 2003)។ ផ្អែកតាមការណែនាំរបស់ស្ថាប័នមានសមត្ថកិច្ច គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាដែលបណ្តុះបណ្តាលចាប់ពីថ្នាក់បរិញ្ញាបត្រទាំងអស់ត្រូវវាយតម្លៃគុណភាពអប់រំរបស់ខ្លួន សំដៅឱ្យគុណភាពស្របតាមស្តង់ដាអន្តរជាតិ។ ប៉ុន្តែ ការវាយតម្លៃធ្វើឡើងដោយ គ.ទ.ក តាមរយៈការស្នើសុំរបស់គ្រឹះស្ថានឧត្តមសិក្សាសាមី គឺជាគោលការណ៍ស្ម័គ្រចិត្ត និងពុំទាន់មានលក្ខណៈចាប់បង្ខំឱ្យអនុវត្តតាមការណែនាំឱ្យខានតែបាននោះទេ។ ក្រោយការចុះពិនិត្យ និងវាយតម្លៃ គ.ទ.ក និងផ្តល់អនុសាសន៍ទៅគ្រឹះស្ថាននោះទៅតាមលក្ខណៈបច្ចេកទេស និងស្តង់ដាអប្បរមា តែពុំមានលក្ខណៈដាច់ខាត ត្រូវតែអនុវត្តនោះទេ។ ក្នុងន័យនេះ ការវាយតម្លៃ និងការផ្តល់អនុសាសន៍ត្រឡប់របស់ គ.ទ.ក. គ្រឹះស្ថានឧត្តមសិក្សាពុំអនុវត្តទាំងស្រុងនោះទេ ដែលទាមទារការចូលរួម និងកិច្ចខិតខំប្រឹងប្រែងរបស់គ្រឹះស្ថានឧត្តមសិក្សាសាមី។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្តីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

ទោះបីមានស្តង់ដាតម្រូវឱ្យសាលាអនុវត្តលើសេវានិស្សិត តែភាគច្រើន មិនសូវបានអនុវត្តពេញលេញនៅឡើយទេ។ ការវាយតម្លៃនេះទៀតសោតជាគោលការណ៍ស្ម័គ្រចិត្តរបស់គ្រឹះស្ថានឧត្តមសិក្សាសាមី។ អនុសាសន៍ដែលទទួលបាន និងបង្ហាញជូនគ្រឹះស្ថានឧត្តមសិក្សានោះ ដែលការអនុវត្ត ឬអត់ ជាការសម្រេចចិត្តរបស់គ្រឹះស្ថាន។ (R1)

លទ្ធផលនៃការស្រាវជ្រាវនេះមានភាពស្រដៀងគ្នានឹង the World Bank (1994, 1997) ដែលបានរកឃើញថា គ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍជួបប្រទះបញ្ហាប្រឈមមួយក្នុងក្នុងការកសាងគុណភាព និងលើកកម្ពស់សេវានិស្សិត។ ស្របនឹងការស្រាវជ្រាវមួយនៅប្រទេសម៉ាឡេស៊ីតាមបែបបរិមាណវិស័យ Selim and Muhammad (2014)បានរកឃើញថា គុណភាពសេវានៅគ្រឹះស្ថានមានចំនួនប្រាំពីរ រួមមានសេវារដ្ឋបាល ការសម្របសម្រួលដាក់ស្តែងកម្មវិធីសិក្សា បុគ្គលិកអប់រំ ការបង្រៀន ការគោរពនិងចំណេះដឹងក្នុងការផ្តល់សេវា និងការយកចិត្តទុកដាក់ដល់អតិថិជនបន្តជាបញ្ហា។

*ការធ្វើប្រតិភូកម្មអំណាចទៅគ្រឹះស្ថានឧត្តមសិក្សា*

ការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងជាបន្តបន្ទាប់ នាំឱ្យការអនុវត្តការងារមួយចំនួនជួបការរាំងស្ទះ យឺតយ៉ាវក្នុងការអនុវត្ត និងពុំទាន់មានគុណភាព។ ការដឹកនាំ និងគ្រប់គ្រងតាមបែបមជ្ឈការត្រូវបានកែសម្រួលមកវិមជ្ឈការ និងសហវិមជ្ឈការសំដៅបង្កើតប្រសិទ្ធភាពផ្តល់សេវា និងប្រសិទ្ធភាពការងារ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តជាច្រើនលើការងារដឹកនាំ និងគ្រប់គ្រង ឱ្យការសម្រេចចិត្តនេះបានទៅលើប្រធានអង្គភាពថ្នាក់ក្រោម។ ជាក់ស្តែងការផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាម៉ីក្នុងការងារដឹកនាំ និងថវិកា តាមរយៈ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ប៉ុន្តែការអនុវត្តជាប្រពៃណីបានបន្តជក់ជាប់ក្នុងការងារគ្រប់គ្រងនៅថ្នាក់ក្រោម ជាមួយនឹងការព្រួយបារម្ភ គួបផ្សំជាមួយនឹងស្ថានភាពមិនច្បាស់លាស់ផង គ្រឹះស្ថានឧត្តមសិក្សានៅតែបន្តលើកឡើងពីការទន្ទឹងរង់ចាំគោលការណ៍ សេចក្តីណែនាំ និងអនុសាសន៍ពីថ្នាក់ដឹកនាំដដែល។ ការអនុវត្តសកម្មភាពការងារណាមួយក្នុងគ្រឹះស្ថានប្រើប្រាស់នូវខ្លឹមសាររួមមួយគឺ ខ្លាចខុសការណែនាំ និងមិនទាន់មានការណែនាំនៅឡើយជាដើម។ តាមពិត លិខិតបទដ្ឋានខាងលើ បានបញ្ជាក់យ៉ាងច្បាស់ និងចង្អុលចំៗឱ្យថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សាមានស្វ័យអំណាចក្នុងការអនុវត្តលើការងារក្នុងដែនរបស់ខ្លួន ដោយពុំចាំបាច់ទន្ទឹងរង់ចាំការណែនាំអ្វីនោះទេ។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្តីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

> លិខិតបទដ្ឋានគតិយុត្តបានបញ្ជាក់ថា សាកលវិទ្យាល័យត្រូវរៀបចំសេវានិស្សិតដោយខ្លួនឯង មិនគួររង់ចាំក្រសួងបញ្ចុកបាយនោះទេ ព្រោះលិខិតខាងលើ គ្រឹះស្ថានមានសិទ្ធិក្នុងការរៀបចំ និងអនុវត្ត។ ការរៀបចំប្រែក្លាយជាគ្រឹះស្ថានសាធារណរដ្ឋបាលគឺដើម្បីផ្តល់ស្វ័យភាពដូចមានចែងក្នុងព្រះរាជក្រឹត្យស្តីពីការប្រែក្លាយជាគ្រឹះស្ថានសាធារណរដ្ឋបាល ត្រង់មាត្រា១ថា " ជានាស័កសិទ្ធភាព នៃការដឹកនាំគ្រប់គ្រង និងអនុវត្តបេសកកម្មរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ស្របតាមគោលការណ៍នយោបាយ និងយុទ្ធសាស្ត្រដែលកំណត់ដោយក្រសួង និងស្ថាប័នអាណាព្យាបាល "។ ន័យនេះ គឺគ្រប់គ្រងលុយគ្រប់គ្រងមនុស្សឱ្យបានល្អ។ អតិថិជនទី១របស់សាកលវិទ្យាល័យគឺនិស្សិត។សេវានិស្សិតគឺជារឿងរបស់សាកលវិទ្យាល័យសុទ្ធសាធ តែសាកលវិទ្យាល័យភ្លេចភារកិច្ចរបស់ខ្លួន។ R2

លទ្ធផលនៃការស្រាវជ្រាវនេះស្រដៀងនឹង Chealy (2006) ដែលបានលើកឡើងថាគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជាដើរតួនាទីសំខាន់ក្នុងធានាគុណភាពអប់រំនៅឧត្តមសិក្សា តែការបង្កើតស្ថាប័ននេះក្រោយការបង្កើតគ្រឹះស្ថានឧត្តមសិក្សាជាច្រើន ដែលនេះជាផលលំបាកក្នុងការធានាគុណភាព។

*ថ្នាក់គ្រឹះស្ថានឧត្តមសិក្សា*

គ្រឹះស្ថានជាតួអង្គសំខាន់ជាងគេដែលអ្នកចូលរួមការស្រាវជ្រាវបានលើកឡើងជាច្រើនដង និងទាមទារឱ្យតួអង្គនេះបំពេញភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ និងមានគុណភាពខ្ពស់ ព្រោះគ្រឹះស្ថានឧត្តមសិក្សាជាប្រតិបត្តិករផ្ទាល់លើផ្នែក

សេវានិស្សិតតែម្តង។ ប៉ុន្តែគ្រឹះស្ថានឧត្តមសិក្សាពុំទាន់បានអនុវត្តបេសកម្មនៅផ្នែកសេវានិស្សិតបានល្អប្រសើរ និងឆ្លើយតបទៅនឹងតម្រូវការរបស់និស្សិតនៅឡើយ។ ភាគច្រើនលើសលុប គ្រឹះស្ថានឧត្តមសិក្សាកំណត់អាទិភាពខ្លាំងបំផុតចំពោះការផ្តល់សេវានិស្សិត គឺមើលទៅលើការរៀន និងបង្រៀន ច្រើនជាងសកម្មភាពផ្សេងៗដូចដែលបានបញ្ជាក់ក្នុងព្រះរាជក្រឹត្យ និងសេចក្តីណែនាំ។ សេវានិស្សិតគឺត្រូវផ្តោតលើគោលនយោបាយជ្រើសរើសនិស្សិត មុខវិជ្ជាចាំបាច់ ការកំណត់ថ្លៃសិក្សា ការផ្តល់អាហារូបករណ៍ សេវាផ្សេងៗដូចជាការផ្តល់អន្តេវាសិកដ្ឋាន ការកំសាន្ត កីឡា និងការផ្តល់សេវាសហគមន៍ (Royal Degree, 2003)។ សេវានិស្សិតត្រូវរួមចំណែកអភិវឌ្ឍចំណេះដឹង សមត្ថភាព និងជំនាញរបស់និស្សិតចាប់ពីការចុះឈ្មោះចូលរៀន រហូតបានបញ្ចប់ការសិក្សាដោយជោគជ័យ ដែលគ្រឹះស្ថានត្រូវកំណត់លក្ខខណ្ឌចូលរៀន ផ្តល់បរិយាកាសឱ្យនិស្សិតអភិវឌ្ឍផ្នែកវប្បធម៌ សង្គម សីលធម៌ ប្រាជ្ញា និងកាយសម្បទា ដែលការផ្តល់សេវានេះត្រូវផ្តោតលើការវាយតម្លៃពីតម្រូវការរបស់និស្សិត (ACC, 2009, 2015)។

ផ្អែកតាមលិខិតបទដ្ឋានខាងលើ គ្រឹះស្ថានឧត្តមសិក្សាមានមុខងារ និងភារកិច្ច ដោយត្រូវធានាឱ្យការសិក្សារបស់និស្សិតក្នុងគ្រឹះស្ថានរបស់ខ្លួនទទួលបាននូវការគាំពារ ប្រឹក្សាយោបល់ អភិវឌ្ឍសមត្ថភាព និងជំនាញ ឈានទៅទទួលបានជោគជ័យក្នុងជីវិតសិក្សានៅសាកលវិទ្យាល័យ។ គ្រឹះស្ថានត្រូវរៀបចំគោលការណ៍ ការណែនាំច្បាស់លាស់ និងផែនការសកម្មភាពគត់មត់ ដើម្បីឆ្លើយតបទៅនឹងបេសកកម្មរបស់ខ្លួនលើផ្នែកសេវានិស្សិត។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្តីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

> អាងថាជាគ្រឹះស្ថានរដ្ឋ បានប្លង់រឹង បុគ្គលិករដ្ឋ ប្រាក់បៀវត្សរដ្ឋ ទឹកភ្លើងរដ្ឋ មិនសូវខ្វល់ទោះនិស្សិតមករៀន ឬអត់ ព្រោះអាងថាសញ្ញាបត្រចេញដោយគ្រឹះស្ថានឧត្តមសិក្សារដ្ឋ។ តែការពិតគេមិនសម្លឹងមើលលើសាលានេះទេ គឺសម្លឹងមើលលទ្ធផលបួនឆ្នាំក្រោយ និស្សិតរៀនចប់ចេះអ្វី ធ្វើការកន្លែងណាបាន ប្រាក់ខែខ្ពស់ឬអត់ ភាគរយនិស្សិតរៀនចប់មានការងារធ្វើត្រូវជំនាញដូចម្តេច ប្រាក់ខែសមរម្យនឹងទីផ្សារ ទើបបង្ហាញពីគុណភាព។ R2

លទ្ធផលស្រាវជ្រាវនេះមានចំណុចដូចគ្នាទៅនឹងលទ្ធផលស្រាវជ្រាវ National Youth Development Council and UNFPA (2000) ដែលបានរកឃើញថាគ្រឹះស្ថានឧត្តមសិក្សាពុំបានយកចិត្តទុកដាក់ក្នុងការផ្តល់សេវានិស្សិត និងសេវាដែលមានស្រាប់ក៏មិនបានទាន់ពេលវេលាថែមទៀតផង។

### *ប្រព័ន្ធផ្តល់សេវា៖ រចនាសម្ព័ន្ធ គោលការណ៍ណែនាំ និងការជូនដំណឹង*

ការរៀបចំសេវាគាំទ្រនិស្សិត ឬប្រឹក្សានិស្សិតពុំមានបែងចែកច្បាស់លាស់ក្នុងរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន ឧត្តមសិក្សានៅឡើយ ដោយការបំពេញការងារជួយគាំទ្រនិស្សិតដែលគ្រឹះស្ថានឧត្តមសិក្សាបានផ្តល់ជូននិស្សិតនោះគឺនៅចម្រុះតាមផ្នែកផ្សេងៗពីគ្នាទៅវិញ ដែលជាហេតុធ្វើឱ្យការទទួល និងការផ្តល់សេវានិស្សិតនៅដាច់ដោយឡែក។ លទ្ធផលនេះពិតជាធ្វើឱ្យការបំពេញមុខងារ និងភារកិច្ចជួយនិស្សិតមិនបានពេញលេញ គ្រប់ជ្រុងជ្រោយ មានគុណភាព និងឆ្លើយតបទៅនឹងតម្រូវការនិស្សិត ព្រោះប្រព័ន្ធការងារមិនទាន់មានភាពច្បាស់លាស់ ពុំមានអ្នកទទួលបន្ទុកត្រឹមត្រូវ។ ការផ្តល់ជូនសេវានិស្សិតហាក់មានលក្ខណៈដើម្បីគ្រាន់តែបន្ទន់ចិត្តនិស្សិតម្តងម្កាលពេលជួបរឿងតវ៉ា ហើយសេវានោះនឹងបាត់បង់ទៅវិញដោយស្វ័យប្រវត្តិពេលករណីនេះបញ្ចប់។ ពេលករណីថ្មីកើតឡើង គ្រឹះស្ថានឧត្តមសិក្សានោះក៏រៀបចំការជួយ

និស្សិតម្តងទៀត។ យន្តការក្នុងការដោះស្រាយបញ្ហានិស្សិតក៏នៅមិនទាន់មានភាពច្បាស់លាស់ និងអនុវត្តបានត្រឹមត្រូវនោះទេ។ និស្សិតជាអ្នកទទួលសេវាបានត្អូញត្អែរលើការពុំយកចិត្តទុកដាក់បានពេញលេញ និងគិតគូរពីជីវិតសិក្សានៅសាកលវិទ្យាល័យរបស់ពួកគេ ដែលជាហេតុធ្វើឱ្យពួកគេបាត់បង់កម្លាំងចិត្ត គ្មានគោលដៅបន្តការសិក្សា និងឈានទៅសម្រេចបោះបង់ការសិក្សាតែម្តង។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្តីរបស់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

> ការរៀបចំសេវានិស្សិតមានលក្ខណៈរប៉ាត់រប៉ាយនៅឡើយ។ មហាវិទ្យាល័យធ្វើត្រឹមមហាវិទ្យាល័យ ឬដេប៉ាតឺម៉ង់ ធ្វើត្រឹមដេប៉ាតឺម៉ង់ មិនមានជាច្រកចេញចូលតែមួយ។ ពុំទាន់មានរចនាសម្ព័ន្ធច្បាស់លាស់នេះ គឺផ្នែកណាផ្តល់សេវាអី ផ្តល់ទៅ មិនទាន់មានជាគោលការណ៍ និងផែនការឱ្យនិស្សិតទៅរកមានគោលដៅច្បាស់លាស់។ R1

គ្រឹះស្ថានឧត្តមសិក្សាមិនទាន់បានរៀបចំរចនាសម្ព័ន្ធត្រឹមត្រូវ ហើយការផ្តល់សេវានិស្សិតមួយចំនួនគឺប្រើប្រាស់និស្សិតស្ម័គ្រចិត្ត ដែលពុំទាន់មានប្រសិទ្ធភាព។ ដូចការលើកឡើងក្នុងសម្រង់សម្តីរបស់ប្រធានការិយាល័យគ្រឹះស្ថានឧត្តមសិក្សាដូចខាងក្រោម៖

> សាកលវិទ្យាល័យពុំបានរៀបចំរចនាសម្ព័ន្ធការងារលើផ្នែកសេវានិស្សិតបានច្បាស់លាស់នោះទេ ការផ្តល់សេវានិស្សិតនៅតាមច្រកផ្សេងៗគ្នា។ សាលាមានដាក់ឈ្មោះផ្នែកប្រឹក្សានិស្សិតដែរ តែមិនមានបុគ្គលិករដ្ឋណាម្នាក់ទទួលបន្ទុក និងមានការកំណត់ការងារច្បាស់លាស់។ និស្សិតស្ម័គ្រចិត្តជាអ្នកមកប្រចាំការ ហើយការពិតណាស់ និស្សិតជួយបានត្រឹមអ្វីដែលគាត់ធ្លាប់ឆ្លងកាត់ និងបានដឹងតែប៉ុណ្ណោះ តែការប្រឹក្សាស៊ីជម្រៅ និងឆ្លើយតបនៅនឹងតម្រូវការនិស្សិតនៅមានកម្រិតឆ្ងាយ។ R7)

លទ្ធផលនៃការស្រាវជ្រាវនេះដូចគ្នានឹងលទ្ធផលរបស់ Sandeen and Barr (2006) ដែលបានលើកឡើងថាការរៀបចំរចនាសម្ព័ន្ធសេវានិស្សិតឱ្យបានល្អពិតជាមានឥទ្ធិពលលើលំហូរការងារ និងប្រសិទ្ធភាពការងារ។ ការមិនទាន់បង្កើតការិយាល័យផ្តល់សេវានិស្សិតបានត្រឹមត្រូវ នៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ព្រោះការបង្កើតការិយាល័យថ្មី ត្រូវឆ្លងកាត់ការសម្រេចពីថ្នាក់ដឹកនាំក្រសួងអាណាព្យាបាលបច្ចេកទេស និងក្រសួងមុខងារសាធារណៈ។ លទ្ធផលនេះដូចគ្នាទៅនឹងការលើកឡើងរបស់ថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សា ដូចខាងក្រោម៖

> ការពិតយើងមិនទាន់មានបង្កើតការិយាល័យប្រឹក្សានិស្សិតចំតែម្តងនោះទេ ព្រោះការបង្កើតនេះជាប្រអប់មុខងារមួយ ដែលទាមទារឆ្លងការសម្រេចពីថ្នាក់ដឹកនាំតាមឋានានុក្រម ព្រោះជាប្រអប់ក្នុងក្របខណ្ឌរដ្ឋ។ សេវាជួយនិស្សិតមាននៅតាមការិយាល័យផ្សេងៗស្រាប់ទៅហើយ ទោះបីមិនទាន់ប្រើឈ្មោះថាសេវាប្រឹក្សានិស្សិត។ ការិយាល័យសិក្សាជួយលើផ្នែករៀន និងបង្រៀន ការិយាល័យ ទំនាក់ទំនងអន្តរជាតិជួយលើការផ្សព្វផ្សាយពីព័ត៌មាន និងឱកាសអាហារូបករណ៍ដល់និស្សិត រួមជាមួយនឹងការសម្របសម្រួលលើការរៀបចំឯកសារជូននិស្សិតស្របតាមតម្រូវការកម្មវិធីនីមួយៗផងដែរ។ កាផ្តល់ឱកាសដល់និស្សិតស្ម័គ្រចិត្តជួយនិស្សិតគ្នាគាត់ ព្រោះយើងយល់ថា និស្សិតគាត់យល់ពីតម្រូវការនិស្សិតបានល្អជាងយើង ហើយយើងគ្រាន់តែជួយគាត់ពីក្រោយ នៅតាមសំណើរបស់និស្សិតស្ម័គ្រចិត្ត។ R3

សេវាសហគមន៍ និងសកម្មភាពសង្គមមួយចំនួនដែលគ្រឹះស្ថានបានផ្តល់ ដើម្បីអនុញ្ញាតឱ្យនិស្សិតមានលទ្ធភាពអនុវត្តចំណេះដឹងបន្ថែមតាមរយៈការអនុវត្តជាក់ស្តែងនោះ ពុំទាន់ត្រូវបានគ្រឹះស្ថានឧត្តមសិក្សាលើកទឹកចិត្ត និងមានគោលការណ៍ច្បាស់លាស់ ដើម្បីឈានទៅរាប់បញ្ចូលសកម្មភាពការងារទាំងនោះជាក្រេឌីតក្នុងកម្មវិធីសិក្សានៅឡើយ។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្តីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

> គ្រឹះស្ថានឧត្តមសិក្សាធ្វើការងារសេវាសហគន៍ដែរ តែធ្វើតាមការនឹកឃើញ ពុំទាន់មានគោលការណ៍ច្បាស់លាស់ដូចជានិស្សិតត្រូវចូលរួមសហគមន៍ប៉ុន្មាន ដើម្បីបញ្ចប់ការសិក្សា។ នៅស្រុកគេ គេតម្រូវឱ្យនិស្សិតមានសកម្មភាពសហគមន៍ ដើម្បីបង្គ្រប់ក្រេឌីតបញ្ចាប់ការសិក្សា និងហួតដល់ឈានទៅមានសេវាសហគមន៍នៅក្រៅប្រទេសទៀតផង។ R1

លទ្ធផលនេះស្រដៀងនឹងលទ្ធផលរបស់ Lim (1999) ដែលរកឃើញថា គ្រឹះស្ថានឧត្តមសិក្សារបស់ប្រទេសកំពុងអភិវឌ្ឍទទួលអន្តរាគមន៍នយោបាយពីថ្នាក់ដឹកនាំ។ កត្តានេះគ្រឹះស្ថានពុំមានគោលការណ៍រៀបចំសកម្មភាពនិស្សិតបានត្រឹមត្រូវនោះឡើយ គឺធ្វើឡើយដើម្បីបម្រើប្រយោជន៍នយោបាយក្នុងពេលចាំបាច់។ លទ្ធផលស្រាវជ្រាវរបស់ Ban and Heng (2023)ក៏បានបង្ហាញពីបញ្ហាប្រឈមរបស់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដោយសារការធ្វើអន្តរាគមន៍ពីនយោបាយផងដែរ។

ការផ្តល់ព័ត៌មានពីសេវាគាំទ្រនិស្សិតរបស់គ្រឹះស្ថាន មិនទាន់បានទូលំទូលាយនៅឡើយ ដែលធ្វើឱ្យនិស្សិតជួបការលំបាក មិនដឹងថា បញ្ហានេះ ករណីនេះ គួរទទួលជួបការផ្តល់ប្រឹក្សា និងណែនាំនៅផ្នែកណា និងនៅទីតាំងណានោះទេ។ និស្សិតជាច្រើនបានមើលមុខគ្នា និងសើច នៅពេលទទួលសំណួរថា ប្អូនមានដឹងថា គ្រឹះស្ថានបានផ្តល់គាំទ្រ និងជួយនិស្សិតអ្វីខ្លះ។ ចម្លើយដូចគ្នារបស់និស្សិតលើកឡើងថា ពួកគាត់មិនបានដឹងថា រាល់ថ្ងៃគ្រឹះស្ថានបានផ្តល់សេវាគាំទ្រ និងជួយនិស្សិតអ្វីខ្លះនោះទេ ព្រោះអ្វីដែលគាត់បានឃើញ គឺមានតែការរៀន និងបង្រៀន និងមានពេលខ្លះរៀបចំកម្មវិធីសិក្ខាសាលាមួយចំនួន។ សេវាប្រឹក្សាលើការសិក្សា ការងារ និងសុខភាពផ្លូវចិត្ត ជាផ្នែកសំខាន់ជួយនិស្សិត តែនិស្សិតមួយចំនួនមិនបានដឹងថា គួរទៅទទួលសេវានោះដោយរបៀបណានោះដែរ។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្តីនិស្សិតដូចខាងក្រោម៖

> ពេលជួបបញ្ហាក្នុងពេលសិក្សា មិនដឹងថា គួត្រូវទាក់ទងទៅនរណា នៅកន្លែងណានោះទេ គិតថា សក់នរណា ក្បាលអ្នកហ្នឹង។ ដើម្បីដោះស្រាយបញ្ហានេះត្រូវសម្រួលអារម្មណ៍ តាំងចិត្ត ប្រាប់ខ្លួនឯងថា ស៊ូទ្រាំ។ ធ្លាប់លឺគេថា មានក្រុមនិស្សិតជួយ តែមិនដឹងថា នៅកន្លែងណា ជួបដោយរបៀបណានោះទេ។ R9)

ខណៈសាកលវិទ្យាល័យឆ្លើយតបថាការផ្តល់ព័ត៌មានរបស់សាកលវិទ្យាល័យ គឺមានច្រកច្រើន និងមានការបង្កើតប្រព័ន្ធបណ្តាញសង្គមមួយចំនួនដូចជាការបង្កើតហ្វេសបុកផេកផ្លូវការរបស់សាលា និងក្រុមតេលេក្រាមរបស់និស្សិតតាមជំនាញ និងជំនាន់។ តែសាកលវិទ្យាល័យផ្តល់ព័ត៌មានទាំងនេះភាគច្រើនគឺផ្តោតលើការជូនដំណឹងពីការសិក្សានិងការបង់ថវិកាតែប៉ុណ្ណោះ។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្តីប្រធានការិយាល័យក្នុងគ្រឹះស្ថានឧត្តមសិក្សាដូចខាងក្រោម៖

យើងផ្តល់សេវាប្រឹក្សាជាមួយនិស្សិតតាមរយៈការបង្កើតគ្រុបតេលេក្រាមតាមជំនាន់នីមួយៗ ដើម្បីជូនដំណឹងស្តីពីការចូលរៀន ថ្ងៃបង់លុយ កាលវិភាគសិក្សា និងគ្រូបង្រៀនជាដើម។ R8

### *ធនធានមនុស្ស៖ គុណវុឌ្ឍិ និងអ្នកជំនាញផ្តល់សេវា*

សេវាសុខភាព និងសង្គ្រោះបឋមជាផ្នែកសំខាន់មួយដែលគ្រឹះស្ថានឧត្តមសិក្សាត្រូវយកចិត្តទុកដាក់ខ្ពស់។ គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំគោលការណ៍ស្តីពីសេវាសុខភាព និងកម្មវិធីអប់រំសុខភាព ដើម្បីជួយនិស្សិតឱ្យបានស្វែងយល់ ចេះព្យាបាល និងការបង្ការជំងឺផ្សេងៗ (ACC, 2023)។ អ្នកចូលរួមស្រាវជ្រាវបានលើកឡើងព្រមគ្នា និងទទួលស្គាល់ថាគ្រឹះស្ថានឧត្តមសិក្សាពុំទាន់បានយកចិត្តទុកដាក់ខ្លាំងលើផ្នែកផ្តល់សេវាសុខភាព និងសង្គ្រោះបឋមដល់និស្សិតនៅឡើយ ដោយការខ្វះខាតបុគ្គលិក និងពុំទាន់បានរៀបចំទីតាំងសមរម្យនិងត្រឹមត្រូវ។ ការអនុវត្តសេវារាល់ថ្ងៃគឺមានការចូលរួមពីក្រុមការងារយុវជនស្ម័គ្រចិត្តរបស់សាកលវិទ្យាល័យដែលធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល និងមានបទពិសោធលើការងារសង្គ្រោះបឋមតែប៉ុណ្ណោះ ហើយការផ្តល់សេវានេះទៀតសោត គ្រឹះស្ថានពុំទាន់មានពេទ្យជំនាញមកប្រចាំការនោះដែរ។ ស្របពេលដែលគ្រឹះស្ថានឧត្តមសិក្សាមួយបានលើកឡើងថា មានគ្រូពេទ្យប្រចាំការ តែគាត់មានវ័យចំណាស់ទៅហើយ ការផ្តល់ផ្តល់សេវានេះមិនបានពេញម៉ោងនោះទេ គឺមានពេលសម្រាកដូចម៉ោងការងារធម្មតា។ លទ្ធផលនេះបានរកឃើញដូចគ្នាទៅនឹងសម្រង់សម្តីប្រធានការិយាល័យសិក្សានៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ដូចខាងក្រោម៖

> ពេលនិស្សិតគាត់មានបញ្ហាសុខភាព គាត់អាចមកបន្ទប់និស្សិតស្ម័គ្រចិត្តដែលមាននិស្សិតនៅប្រចាំការទីនោះ។ យើងមិនទាន់មានពេទ្យជំនាញនោះទេ គឺនិស្សិតជួយការងារនេះធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលបឋម និងការប្រឹក្សាខ្លះ។ តែបើសង្កេតឃើញថា សភាពកូនសិស្សមិនស្រួលនោះទេ យើងបញ្ជូនគាត់ទៅកាន់មន្ទីរពេទ្យដែលនៅក្បែរនេះភ្លាមៗតែម្តង។ R8

លទ្ធផលនៃការស្រាវជ្រាវនេះដូចនឹងការលើកឡើងរបស់ the World Bank (1994) បានបញ្ជាក់ថាគ្រឹះស្ថានឧត្តមសិក្សាប្រទេសកំពុងអភិវឌ្ឍជួបបញ្ហាកង្វះខាតធនធានមនុស្ស និងប្រសិទ្ធភាពក្នុងការបំពេញការងារ។ បន្ថែមពីនេះ Jaswinderet et al. (2008) លើកឡើងថា ទោះបីគ្រឹះស្ថានឧត្តមសិក្សាបានរៀបចំសេវាប្រឹក្សាយ៉ាងសំបូរបែប ដើម្បីផ្តល់យន្តការគាំទ្រ និងលើកទឹកចិត្តនិស្សិតពេលកំពុងសិក្សាក្នុងគ្រឹះស្ថានរបស់ខ្លួនក៏ពិតមែន តែពុំធានាថាអាចជួយនិស្សិតទៅតាមតម្រូវការរបស់គាត់នោះទេ បើអ្នកផ្តល់សេវា ឬសេវានិស្សិតពុំមានគុណភាពសមត្ថភាព។ លើសពីនេះ Sandeen (1988) បានលើកឡើងថាបញ្ហាប្រឈមមួយផ្សេងទៀតគឺកង្វះការបណ្តុះបណ្តាលលើជំនាញនិងវិជ្ជាជីវៈដល់បុគ្គលិកបម្រើការងារក្នុងផ្នែកនេះ។ បុគ្គលិកទទួលបានការបណ្តុះបណ្តាលជំនាញបន្ថែមជាប្រចាំនឹងជួយឱ្យគាត់មានលទ្ធភាពកាន់តែល្អប្រសើរក្នុងការផ្តល់សេវាជួយនិស្សិត។

### *ទំនើបកម្មការផ្តល់សេវា*

ទោះបីគ្រឹះស្ថានឧត្តមសិក្សាជាកន្លែងផលិតចំណេះដឹង ស្រាវជ្រាវ និងផ្សព្វផ្សាយពីការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗជូនដល់មហាជន ជាពិសេសនិស្សិត ស្របតាមវិវត្តន៍នៃសកលលោក ជាមួយនឹងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយទាក់ទងនឹងបច្ចេកវិទ្យាបន្តបន្ទាប់ក្នុងការសិក្សា និងស្រាវជ្រាវរាប់មិនអស់ក៏ដោយ តែការផ្តល់សេវានិស្សិតរបស់

សាកលវិទ្យាល័យមួយចំនួនធំនៅបន្តប្រើប្រាស់មធ្យោបាយជាប្រពៃណីដែលត្រូវប្រើប្រាស់ពេលយូរ មានភាពស្មុគស្មាញ ដូចជាការបំពេញពាក្យចូលរៀន ការបង់ប្រាក់ ពាក្យសុំច្បាប់ ការគណនាពិន្ទុ-ទទួលពិន្ទុ និងពិនិត្យ វត្តមាន ជាដើម។ គ្រឹះស្ថានបន្តប្រើប្រាស់ក្រដាសបំពេញ ដែលពុំទាន់បានប្រើប្រាស់បច្ចេកវិទ្យាក្នុងការជួយបង្កើតប្រសិទ្ធភាព កាត់បន្ថយភាពស្មុគស្មាញ និងពេលវេលាដល់និស្សិតនៅឡើយ។ ការអនុវត្តនេះធ្វើឱ្យអ្នកទទួលសេវាត្អូញត្អែរ និងចង់ឱ្យមានការធ្វើទំនើបកម្មក្នុងផ្នែកនេះ ជាបន្ទាន់។លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្ដីក្រុមនិស្សិតខាងក្រោម៖

> ការឈ្មោះចូលរៀននៅបន្តឱ្យមានការបំពេញពាក្យដោយដៃផ្ទាល់ ដែលផ្ដល់ការលំបាកដល់និស្សិត ព្រោះនិស្សិតខ្លះនៅតាមខេត្តហើយមានបំណងចុះឈ្មោះចូលរៀនឱ្យបានលឿន។ ជាពិសេស ការបង់ប្រាក់ត្រូវចំណាយពេលវេលាយូរណាស់ និស្សិតជាច្រើនតម្រង់ជួរគ្នាមកបង់ប្រាក់ ហើយទម្រាំបានដល់ខ្ញុំ ជួនកាលចាំដល់មួយថ្ងៃក៏មាន។ និស្សិតច្រើននាក់មកចាំ បែកញើស និងក្ដៅ។ R9

សេវាទទួលព័ត៌មានពិន្ទុសិក្សារបស់និស្សិតប្រើប្រាស់ពេលវេលាយូរ ដោយត្រូវរង់ចាំការបូកបញ្ចូល និងផ្ទៀងផ្ទាត់ បន្ទាប់ពីបានទទួលពិន្ទុពីគ្រូបង្រៀនគ្រប់គ្រាន់។ ភាពយឺតយ៉ាវទាំងនេះផ្ដល់ផលវិបាកដល់និស្សិតក្នុងការចូលរួមដាក់អាហារូបករណ៍ ឬសកម្មភាពផ្សេងៗដែលទាមទារព្រឹត្តិបត្រពិន្ទុ និងលិខិតបញ្ជាក់ពីគ្រឹះស្ថាន។លទ្ធផលនេះ ដូចគ្នាទៅនឹងការលើកឡើងរបស់ក្រុមនិស្សិតដូចខាងក្រោម៖

> ចង់ដឹងពីពិន្ទុត្រូវទៅសុំនៅការិយាល័យសិក្សា ពេលខ្លះទោះប្រឡងឆមាសចប់យូរថ្ងៃហើយ តែពិន្ទុនៅមិនទាន់បានទទួលទេ ដោយគាត់ថា គ្រូបង្រៀននោះមិនទាន់ផ្ដល់ពិន្ទុឱ្យ។ ពេលខ្លះត្រូវការដាក់ពាក្យអាហារូបករណ៍ដែលតម្រូវភ្ជាប់ជាមួយពិន្ទុត្រូវបានខកខានថែមទៀត។ មកដល់សម័យនេះហើយ សាលាគួររៀបចំប្រព័ន្ធមួយ ដើម្បីផ្ដល់ភាពងាយស្រួលដល់និស្សិតលើការងារចុះឈ្មោះចូលរៀន និងការបង់លុយជាដើម។ R10

លទ្ធផលនេះដូចគ្នានឹងលទ្ធផលរបស់ the World Bank (2000) ដែលរកឃើញថាគ្រឹះស្ថានឧត្ដមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍជួបប្រទះកង្វះហេដ្ឋារចនាសម្ព័ន្ធ សម្ភារពិសោធន៍ និងសម្ភារជួយដល់ការសិក្សារបស់និស្សិត។ ជាការពិត ស្របតាមការប្រែប្រួល និងការវិវត្តនៃបច្ចេកវិទ្យាសម្ភារសិក្សា និងឧបករណ៍មួយចំនួនត្រូវការជាចាំបាច់ ដើម្បីបង្កើនសមត្ថភាពអនុវត្ត និងពិសោធន៍ជាក់ស្ដែងសម្រាប់និស្សិត។

គ្រឹះស្ថានឧត្ដមសិក្សារដ្ឋតែមួយគត់បានផ្ដល់សេវាគាំទ្រនិស្សិត ដោយជំនួសដោយបច្ចេកវិទ្យា ក្រោមហេតុផលដើម្បីបង្កើតប្រសិទ្ធភាពការផ្ដល់សេវា និងផ្ដល់ភាពងាយស្រួលជូននិស្សិត។ គ្រឹះស្ថានឧត្ដមសិក្សាបានរៀបចំប្រព័ន្ធចុះឈ្មោះចូលរៀន ការបង់ប្រាក់ ការចុះវត្តមាន ការទទួលពិន្ទុ និងបញ្ជូនពិន្ទុទៅនិស្សិត និងកម្មវិធីផ្សព្វផ្សាយផ្សេងទៀតតាមប្រព័ន្ធបច្ចេកវិទ្យាតែម្ដង។ ការធ្វើទំនើបកម្មពិតជាធ្វើឱ្យនិស្សិតកាន់តែមានភាពកក់ក្ដៅ និងផ្ដល់ភាពងាយស្រួលដល់ការសិក្សារបស់គាត់។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្ដី ថ្នាក់ដឹកនាំគ្រឹះស្ថានឧត្ដមសិក្សា ដូចខាងក្រោម៖

> សាកលវិទ្យាល័យខ្ញុំមានរៀបចំប្រព័ន្ធចុះឈ្មោះតាម APP និស្សិតលែងចុះឈ្មោះប្រើក្រដាសទៀតហើយ។ពេលនិស្សិតចុះឈ្មោះលើ APP ដែលផ្ដល់ជូន គឺគាត់មានID និងគណនេយ្យរបស់គាត់តែម្ដង ដែលគាត់បានធ្វើការបង់ប្រាក់ផ្ទាល់តែម្ដងមិនចាំបាច់មកបេឡាទៀតនោះទេ។ ការផ្ដល់ព័ត៌មានពី

ការសិក្សា និងកម្មវិធីផ្សេងៗនិងបានដល់និស្សិតតាមកម្មវិធីនេះ។ ជាពិសេស គ្រូបង្រៀនអត់វាយពិន្ទុលើក្រដាសនោះទេ គឺនៅក្នុងAPP មានផ្នែកបញ្ចូលពិន្ទុ ដើម្បីគ្រូអាចចូលក្នុងបញ្ជីឈ្មោះនិស្សិត។ ពេលគ្រូបំពេញរួចរាល់ ចុចធ្វើ នោះពិន្ទុរត់ទៅគណនេយ្យនិស្សិតរៀងៗខ្លួន។ មិនចាំបាច់បិតលើក្ដារខៀន នរណាធ្លាក់ នរណាជាប់ទៀតទេ គឺនិស្សិតដឹងពិន្ទុរបស់គាត់តែម្ដង។ ចំណែកការបង់ប្រាក់លើផ្នែករដ្ឋបាលដូចជាការបញ្ជាក់ការសិក្សា ព្រឹត្តិបត្រពិន្ទុជាដើម គឺនិស្សិតបង់តែម្ដងគត់ ហើយអាចប្រើប្រាស់សេវានេះមួយចប់កម្មវិធីតែម្ដង លែងមានភាពស្មុគស្មាញ បង់លុយច្រើនដងៗ។ ចំពោះការគ្រប់គ្រងម៉ោងបង្រៀនរបស់គ្រូ ក៏ប្រើប្រាស់ប្រព័ន្ធនេះដែរ ផ្ដល់ភាពងាយស្រួលក្នុងការគិតពីប្រាក់បង្រៀនរបស់គាត់។ R5

*ថវិកាទ្រទ្រង់*

បញ្ហាថវិកាគឺជាចំណុចសំខាន់មួយសម្រាប់គ្រឹះស្ថានឧត្ដមសិក្សាក្នុងការធ្វើទំនើបកម្មវិធីផ្ដល់សេវានិស្សិត និងពង្រឹងគុណភាពអប់រំស្របតាមបេសកកម្មរបស់ខ្លួន។ ថ្នាក់ដឹកនាំបានបង្ហាញថាបំណងចង់ឱ្យការផ្ដល់សេវាបានរហ័ស និងទាន់ចិត្តសម្រាប់ជូននិស្សិត តែគ្រឹះស្ថានពុំទាន់មានថវិកាគ្រប់គ្រាន់ ដែលតម្រូវឱ្យគ្រឹះស្ថានពង្រឹងនូវចំណុចអាទិភាពសំខាន់ៗមុនដូចជាហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារសិក្សាជាច្រើនផ្សេងទៀត។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្ដីរបស់ថ្នាក់ដឹកនាំគ្រឹះស្ថានឧត្ដមសិក្សា ដូចខាងក្រោម៖

> យើងទទួលបានសំណូមពរច្រើនពីនិស្សិត តែយើងមិនអាចឆ្លើយតបទៅគាត់បានទាន់ពេលវេលានិងផ្ដល់ជូននូវអ្វីដែលគាត់ចង់បានភ្លាមៗនោះទេ។ សាកលមានកិច្ចការជាច្រើនត្រូវធ្វើ ខណៈដែលកញ្ចប់ថវិកាមានកំណត់ ដែលត្រូវបែងចែក និងប្រើប្រាស់ចំពោះការងារអាទិភាពជាមុនសិន ដូចជាអគារសិក្សាជាដើម។ R3

លទ្ធផលនៃការស្រាវជ្រាវនេះដូចគ្នានឹងរបាយការណ៍របស់ the World Bank (2017) ដែលបានបង្ហាញថាគ្រឹះស្ថានឧត្ដមសិក្សាមួយចំនួនក្នុងប្រទេសកំពុងអភិវឌ្ឍជួបប្រទះកង្វះហិរញ្ញវត្ថុ។ ដូចគ្នាដែរ Welch (2008) បានលើកឡើងផងដែរពីកង្វះថវិការបស់គ្រឹះស្ថានឧត្ដមសិក្សាលើផ្នែកសេវានិស្សិត។ បុគ្គលិកបម្រើការងារនៅក្នុងផ្នែកនេះក៏ទទួលបានប្រាក់ខែតិច បើប្រៀបធៀបជាមួយការងារផ្សេងទៀត ដែលជាហេតុធ្វើឱ្យមានការផ្លាស់បុគ្គលិកជាទៀងទាត់ (Hung, 2008)។ ស្របជាមួយនឹង Tilak (2003) ក៏បានលើកឡើងថា ប្រទេសជាច្រើននៅតំបន់អាស៊ានមិនមានលទ្ធភាពក្នុងការលើកកម្ពស់គុណភាពនៅឧត្ដមសិក្សាដោយសារចំនួននិស្សិតច្រើន កង្វះខាតបុគ្គលិក យន្តការពង្រឹងគុណភាព កង្វះសម្ភារបរិក្ខា ឧបករណ៍ពិសោធន៍ និងថវិកាគាំទ្រពីរដ្ឋតិចតួច។ ទន្ទឹមនេះ Keng et al. (2016) ក៏បានលើកឡើងថា គ្រឹះស្ថានឧត្ដមសិក្សាកម្ពុជាជួបបញ្ហាថវិកាក្នុងការបំពេញបេសកកម្មរបស់ខ្លួន។

*លក្ខណសម្បត្តិនៃសេវានិស្សិតល្អ*

ការលើកកម្ពស់គុណភាពសេវានិស្សិតត្រូវបានលើកឡើង និងស្នើឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ និងឱ្យបានខ្ពស់បំផុត ដើម្បីរួមចំណែកជួយគាំទ្រ លើកទឹកចិត្ត និងជំរុញឱ្យនិស្សិតទទួលបានទាំងវិជ្ជាសម្បទា បំណិនសម្បទា

និងចរិយាសម្បទាដូចមានបញ្ជាក់ក្នុងបេសកកម្មសេវានិស្សិត។ អ្នកចូលរួមស្រាវជ្រាវលើកឡើងពីលក្ខណសម្បត្តិនៃសេវានិស្សិតដែលមានបួនចំណុចចម្បង ដូចជា រចនាសម្ព័ន្ធ ធន្ធៈ និងធនធានមនុស្ស យន្តការច្រកចេញចូលតែមួយ ថវិកាទ្រទ្រង់ និងការចូលរួម។

*រចនាសម្ព័ន្ធ ធន្ធៈ និងធនធានមនុស្ស*

រចនាសម្ព័ន្ធផ្នែកសេវានិស្សិតត្រូវមាន ដើម្បីពង្រឹងប្រសិទ្ធភាពការងារឱ្យទទួលបានលទ្ធផលល្អគាប់ និងត្រឹមត្រូវតាមឋានានុក្រម។ ការផ្ដល់សេវា និងការគ្រប់គ្រងដែលពុំទាន់មានរចនាសម្ព័ន្ធ និងពុំទាន់ត្រឹមត្រូវគឺជាឧបសគ្គក្នុងរៀបចំផែនការ គោលការណ៍ សកម្មភាពអនុវត្ត និងត្រួតពិនិត្យលើដំណើរការផ្ដល់សេវានេះ។ ការជ្រើសរើសមនុស្សឱ្យបានត្រឹមត្រូវស្របតាមជំនាញ និងគុណវុឌ្ឍិខ្ពស់ក្នុងការផ្ដល់សេវាជូននិស្សិតជាចំណុចសំខាន់បន្ថែមទៀត។ ធនធានមនុស្សនៅទីនេះចង់សំដៅដល់ពីរប្រភេទគឺ៖ មន្ត្រីជំនាញ និងមន្ត្រីទូទៅ។ មន្ត្រីជំនាញត្រូវទទួលបន្ទុកក្នុងការផ្ដល់សេវាចាំបាច់រួមមាន៖ មន្ត្រីប្រឹក្សាផ្នែកសុខភាព ផ្នែកប្រឹក្សាផ្នែកផ្លូវចិត្ត បច្ចេកវិទ្យា មន្ត្រីផ្នែកប្រឹក្សាការងារជាដើម។ ចំណែកមន្ត្រីទូទៅត្រូវមានទេពកោសល្យផ្នែកជំនាញទន់ ជួយលើសម្របសម្រួលលើការងារទូទៅ ផ្ដល់ព័ត៌មាន និងតម្រង់ទិសជាដើម។ ការមានរចនាសម្ព័ន្ធ និងធនធានមនុស្សត្រឹមត្រូវជួយឱ្យនិស្សិតទទួលបានសេវាប្រឹក្សាល្អ និងមានគុណភាព។ ជាពិសេសការដាក់ចេញផែនការ គោលការណ៍ និងពេលវេលាផ្ដល់សេវាគឺឆ្លើយតបទៅនឹងតម្រូវការនិស្សិត។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្ដី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

> សេវាខ្លះត្រូវការមន្ត្រីបច្ចេកទេស ដើម្បីប្រឹក្សានិស្សិតដូចជាផ្នែកប្រឹក្សាផ្លូវចិត្តឱ្យបានត្រឹមត្រូវ និងជួយនិស្សិតបាន ហើយមិនអាចយកនិស្សិតគ្នាគាត់មកជួយផ្ដល់ប្រឹក្សាគ្នាគាត់លើការងារបច្ចេកទេសបាននោះទេ។ ករណីខ្លះមិនបានជួយហើយ មានតែនាំបញ្ហាដល់និស្សិតថែមទៀត។ ពេលវេលាផ្ដល់សេវានិស្សិតគឺត្រូវស្របពេលគាត់ទំនេរ មិនមែន ពេលគាត់ទំនេរ ត្រូវការសេវា បែរជាអ្នកផ្ដល់សេវាសម្រាកមិនអាចផ្ដល់បាននោះទេ។ R1

ការរៀបចំម៉ោងផ្ដល់សេវានិស្សិតមិនទាន់បានឆ្លើយតបទៅនឹងតម្រូវការនិស្សិតនោះទេ។ និស្សិតចង់ឱ្យគ្រឹះស្ថានឧត្ដមសិក្សាផ្ដល់សេវានិស្សិតនៅពេលគាត់សម្រាកពីការងារ ខណៈដែលម៉ោងសម្រាក និងពេលសម្រាក គឺគ្រឹះស្ថានមិនបានផ្ដល់សេវាដល់និស្សិតនោះឡើយ។ ភាពខ្វែងគ្នាក្នុងការជ្រើសរើសម៉ោងផ្ដល់សេវាបន្តជាបញ្ហាប្រឈមមួយ។ លទ្ធផលនេះមានបង្ហាញក្នុងសម្រង់សម្ដីរបស់និស្សិតដូចខាងក្រោម៖

> ពេលខ្លះយើងទៅទទួលសេវាពីសាលា សាលាមិនធ្វើការ ព្រោះដល់ពេលសម្រាកបាត់។ យើងធ្វើការផងរៀនផង ដើម្បីរកលុយមកបង់ថ្លៃសិក្សា។ យើងអាចមកសាលាបានពេលយើងទំនេរ។ R9

លទ្ធផលនៃការស្រាវជ្រាវនេះដូចការលើកឡើងរបស់ Bresciani (2011) ដែលបញ្ជាក់ថាអ្នកផ្ដល់សេវាប្រកបដោយវិជ្ជាជីវៈត្រូវភ្ជាប់ការងាររបស់ខ្លួនឱ្យអស់លទ្ធភាពទៅនឹងគោលការណ៍រៀនរបស់និស្សិត និងគោលដៅរបស់គ្រឹះស្ថានឧត្ដមសិក្សា។ ស្របគ្នានេះ Brock (2010) បានលើកឡើងថា សេវានិស្សិតល្អត្រូវតែធនធានមនុស្សសម្រាប់ផ្ដល់សេវាឱ្យបានគ្រប់គ្រាន់ ដើម្បីតម្រង់ទិស និងផ្ដល់ ដំណោះស្រាយជូននិស្សិត។  ទន្ទឹមនេះ Good Unversity Guide (2017) បាន

អះអាងថា សេវានិស្សិតល្អពិតជាត្រូវការអ្នកផ្តល់សេវាដែលអាចជួយគាត់នូវគ្រប់បញ្ហាទាំងការសិក្សា និងរឿងផ្ទាល់ខ្លួន។ អ្នកផ្តល់សេវាត្រូវមានភាពរួសរាយ និងមានឆន្ទៈក្នុងការបំពេញការងារ (Emily, 2018)។ ការផ្តល់សេវាប្រព័ន្ធសេវានិស្សិតល្អជួយកាត់បន្ថយនិស្សិតបោះបង់ និងជួយរក្សានិស្សិតឱ្យបន្តការសិក្សាបានជោគជ័យ បើទោះបីនិស្សិតមកពីគ្រួសារក្រីក្រ បញ្ហាសុខភាព ជនជាតិភាគតិច (Chanthavong, 2015)។ បន្ថែមពីនេះ Chet (2006) បានលើកឡើងដូចនឹងលទ្ធផលស្រាវជ្រាវនេះថា ការពង្រឹងគុណភាពនៅឧត្តមសិក្សាពិតជារួមចំណែកមកពីយន្តការនៃការគ្រប់គ្រងបានល្អប្រសើរ។

### *យន្តការច្រកចេញចូលតែមួយ*

គ្រឹះស្ថានឧត្តមសិក្សាគួរពិចារណាបង្កើតច្រកចេញចូលតែមួយ ដែលជាច្រកតែមួយក្នុងការផ្តល់ព័ត៌មាន និងសេវាជូនភាគីពាក់ព័ន្ធ ជាពិសេសនិស្សិតនៅមួយកន្លែង។ ការទទួលសេវាច្រើន នៅទីតាំងផ្សេងគ្នា ធ្វើឱ្យប្រើប្រាស់ពេលវេលាច្រើន និងមានភាពសាំញាំ។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្ភីថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សា ដូចខាងក្រោម៖

> នៅពេលមានច្រកចេញចូលតែមួយ និស្សិតពេញចិត្តជាងការមានសេវានៅរាយប៉ាយតាមកន្លែងមួយធ្វើដោយខ្លួនឯង។ និស្សិតត្រូវការសេវាអ្វីក៏ដោយ មកច្រកចេញចូលតែមួយគាត់ទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ និងបន្តនីតិវិធី។ សព្វថ្ងៃនិស្សិតឆ្នាំទី១មកទទួលសេវានៅថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និស្សិតឆ្នាំទី២ដល់ទី៤ មកទទួលនៅការិយាល័យសិក្សា និងនិស្សិតក្រោយបរិញ្ញាបត្រ ទទួលព័ត៌មាននៅថ្នាក់ក្រោយបរិញ្ញាបត្រ។ R3

លទ្ធផលនៃការស្រាវជ្រាវនេះដូចការលើកឡើង RGC (2017) ដែលបញ្ជាក់ថា ច្រកចេញចូលតែមួយគឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយតាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងគណនេយ្យភាព។ ស្របគ្នាទៅនឹងការលើកឡើងរបស់ Kasmad et al. (2021) បានលើកឡើងពីការតាមរយៈនៃការប្រើប្រាស់យន្តការច្រកចេញចូលតែមួយក្នុងការងារអាជីវកម្ម និងវិនិយោគ។ ដូចគ្នានេះ Turner (2012) ការផ្តល់សេវាតាមរយៈច្រកចេញចូលតែមួយ ត្រូវបានជ្រើសរើសនិងពេញនិយមនៅក្នុងពិភពលោកដែលរដ្ឋាភិបាលប្រើប្រាស់ក្នុងការបង្កើនប្រសិទ្ធភាពផ្តល់សេវា រក្សាភាពបត់បែន និងការធ្វើសមាហរណកម្មរដ្ឋបាលផងដែរ ។

### *ថវិកាទ្រទ្រង់*

កញ្ចប់ថវិកាជាតួអង្គសំខាន់ដើម្បីធានានិរន្តរភាព និងប្រសិទ្ធភាពការងារ។ ពិតណាស់ថាដើម្បីរៀបចំសកម្មភាព និងកម្មវិធីថវិកានឹងត្រូវចំណាយ។ គ្រឹះស្ថានឧត្តមសិក្សាត្រូវមានខ្ទង់ចំណាយសម្រាប់ផ្តោតការយកចិត្តទុកដាក់លើសេវានិស្សិត។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្ភីថ្នាក់ដឹកនាំគ្រឹះស្ថាន ដូចខាងក្រោម៖

> ពេលគ្រឹះស្ថានមានថវិកាគ្រប់គ្រាន់នឹងរៀបចំប្រព័ន្ធផ្តល់សេវាជូននិស្សិតនេះឱ្យកាន់តែល្អប្រសើរ តាមរយៈការរៀបចំនូវប្រព័ន្ធផ្តល់ព័ត៌មាន និងសេវាចាំបាច់ផ្សេងទៀត ដែលកាត់បន្ថយការប្រាស្រ័យ

ទាក់ទងគ្នាផ្ទាល់ ដោយបែរមកប្រើប្រាស់បច្ចេកវិទ្យាមកជំនួស។ ទំនើបកម្មនេះប្រើពេលវេលាតិច និង មានគុណភាព តែត្រូវការមានថវិកាជួយទ្រទ្រង់។ R5

លទ្ធផលនៃការស្រាវជ្រាវនេះដូចគ្នានឹង Husain et al. (2003) ដែលលើកឡើងថាថវិកាផ្តល់ជូនក្នុងវិស័យអប់រំត្រូវតែបង្កើនជាចាំបាច់ ដើម្បីលើកកម្ពស់ធនធានមនុស្សក្នុងប្រទេស។ ស្របគ្នាជាមួយនឹងការលើកឡើងរបស់ Khan (2009) ។ ការវិនិយោគតិចលើធនធានមនុស្សមនុស្សក្នុងតំបន់អាស៊ាននឹងធ្វើឱ្យប្រទេសទាំងនេះពុំមានធនធានមនុស្សគ្រប់គ្រាន់ក្នុងការប្រកួតប្រជែងជាមួយទីផ្សារពិភពលោក និងមិនអាចបង្កើនផលិតភាពខ្ពស់បានទេ។

*ការចូលរួម*

គ្រឹះស្ថានត្រូវបង្កើនទំនាក់ទំនង ជាមួយសហគ្រាសក្នុងការផ្តល់ជាវគ្គបណ្តុះបណ្តាល ការប្រឹក្សាការងារ ទស្សនកិច្ចសិក្សា និងការចុះកម្មសិក្សារបស់និស្សិតជាដើម។ ជាពិសេស ផ្តល់ព័ត៌មានលើការងារស្នាក់នៅដល់និស្សិតមកពីតាមបណ្តាខេត្តឱ្យបានដឹង។ ការចូលរួមនេះសំដៅដល់អ្នកផ្តល់សេវាពាក់ព័ន្ធមួយចំនួនទៀតក្រៅពីការសិក្សាដូចជាផ្នែកអនាម័យ សន្តិសុខសណ្តាប់ធ្នាប់ ចំណតមធ្យោបាយ ហិរញ្ញវត្ថុ ជាដើម ត្រូវការសហការគ្នា និងរួមគ្នាបំពេញការងារឱ្យបានត្រឹមត្រូវ និងឆ្លើយតបទៅនឹងគុណតម្លៃរបស់គ្រឹះស្ថាន។ កិច្ចសហការទាំងនេះផ្តល់ជូននូវទំនុកចិត្ត និងបរិយាកាសសិក្សាល្អ នាំចិត្តនិស្សិតចង់មកសិក្សា និងខិតខំរៀនរៀនសូត្រ។ លទ្ធផលនេះបានបង្ហាញក្នុងសម្រង់សម្តីថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សាដូចខាងក្រោម៖

និស្សិតសាកលវិទ្យាល័យភាគច្រើនមកពីតាមបណ្តាខេត្តនានា ការផ្តល់សេវាប្រឹក្សាលើការងារ ពិតជាបានជួយដល់និស្សិតបានច្រើន។ ព័ត៌មានពីកន្លែងស្នាក់នៅ កាន់តែមានសារសំខាន់ផងដែរ ព្រោះនិស្សិតពិតជាមិនដឹងថា គួរស្នាក់នៅទីណា ស្វែងរកដោយរបៀបដូចម្តេចនោះទេ។ ការចូលរួមពីភាគីពាក់ព័ន្ធត្រឹមតែផ្តល់ធនធានជួយសាកលវិទ្យាល័យតែក៏បានផ្តល់ឱកាសជួយដល់និស្សិតដូចជាព័ត៌មានការងារ ស្នាក់នៅ និងឱកាសការងារតែម្តង។ R6

លទ្ធផលនៃការស្រាវជ្រាវនេះដូចគ្នានឹង Habtom (2020) ដែលបង្ហាញថា ការទំនាក់ទំនងរវាងរដ្ឋនិងគ្រឹះស្ថានដែលគ្មានការចូលរួមពុំមានប្រសិទ្ធភាពនោះទេ ព្រោះខ្វះការចូលរួមពីវិស័យឯកជន ដើម្បីរួមផ្តល់ថវិកាដល់គ្រឹះស្ថាន។ ទន្ទឹមនេះ Dickson et al. (2004) ក៏បានបង្ហាញថាការចូលរួមពីភាគីពាក់ព័ន្ធគឺជាកត្តាជំរុញបង្កើនគុណភាពសេវានិស្សិត។ ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលក៏បានដើរតួនាទីជាដៃគូសំខាន់របស់គ្រឹះស្ថានផងដែរ។ ស្រដៀងគ្នាផងដែររបស់ Chet (2006) បានលើកឡើងដូចគ្នាដែរថា បើគ្មានការចូលរួម ជាមួយការតាំងចិត្តមុតមាំពីគ្រប់ភាគីពាក់ព័ន្ធនោះទេ គុណភាពឧត្តមសិក្សាពិតជាពិបាកក្នុងការលើកកម្ពស់។

សរុបជារួម ការអនុវត្តសេវានិស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋនៅខ្វះចន្លោះ ឬពុំទាន់បានពេញលេញ និងឆ្លើយតបទៅនឹងតម្រូវការនិស្សិត និងអង្គភាពមានសមត្ថកិច្ចនៅឡើយ ដោយសារកត្តាមួយចំនួនទាក់ទងនឹងលិខិតបទដ្ឋានគតិយុត្ត ឆន្ទៈរបស់ថ្នាក់ដឹកនាំ និងការរៀបចំប្រព័ន្ធការងារឱ្យបានប្រសិទ្ធភាព។ លទ្ធផលនៃការស្រាវជ្រាវនេះដូចគ្នាខ្លះ និងស្រដៀងគ្នាខ្លះចំពោះការស្រាវជ្រាវផ្សេងៗទៀតកន្លងមកនៅក្នុងប្រទេសកំពុងអភិវឌ្ឍ និងការរីកចម្រើននៃបច្ចេក

វិទ្យាផងដែរ។ បន្ថែមក្រៅពីនេះ ដើម្បីឈានទៅធ្វើឱ្យប្រសើរឡើងនូវសេវានិស្សិតតាមគ្រឹះស្ថាន លក្ខណសម្បត្តិមួយចំនួនបានលើកឡើង ដើម្បីជាធាតុចូលបន្ថែមទៀតសម្រាប់គ្រឹះស្ថានឧត្តមសិក្សាពិនិត្យ ពិចារណា និងឈានទៅលើកកម្ពស់គុណភាពសេវានិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សា។

## សេចក្តីសន្និដ្ឋាន

ការស្រាវជ្រាវនេះបានបង្ហាញថា បើទោះបីគ្រឹះស្ថានឧត្តមសិក្សារដ្ឋមានស្វ័យភាពក្នុងការងាររដ្ឋបាល និងហិរញ្ញវត្ថុដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តក៏ពិតមែន តែការអនុវត្តជាក់ស្តែងរបស់គ្រឹះស្ថានមិនទាន់បានពេញលេញ ឬមានភាពម្ចាស់ការនៅឡើយក្នុងការអនុវត្ត ឬគំនិតផ្តួចផ្តើមឱ្យមានសកម្មភាពថ្មីៗ ដើម្បីជួយគាំទ្រលើបេសកកម្មរបស់ខ្លួននោះទេ។ ការបន្តរង់ចាំសេចក្តីណែនាំ ឬការជូនដំណឹងពីថ្នាក់ជាតិ ឬការព្រួយបារម្ភក្នុងការអនុវត្តហាក់នៅជាមន្ទិលសម្រាប់គ្រឹះស្ថានឧត្តមសិក្សារដ្ឋនៅឡើយ។ ស្របពេលដែលការពិនិត្យ និងតាមដានការអនុវត្តគុណភាពអប់រំឧត្តមសិក្សាជាការស្ម័គ្រចិត្តទៀតសោត ធ្វើឱ្យគ្រឹះស្ថានឧត្តមសិក្សាទាំងនោះ កាន់តែមិនទាន់បានយកចិត្តទុកដាក់ខ្លាំងលើលក្ខខណ្ឌតម្រូវរបស់អង្គភាពថ្នាក់ជាតិ។ ជាពិសេស ការអនុវត្តមុខងារ និងភារកិច្ចរបស់ថ្នាក់ជាតិ និងគ្រឹះស្ថានឧត្តមសិក្សាលើសេវានិស្សិតមានការបកស្រាយផ្សេងៗពីគ្នា។

ការស្រាវជ្រាវនេះបានបង្ហាញថា ការអនុវត្តសេវានិស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋពុំទាន់បានត្រឹមត្រូវនៅឡើយនោះទេ បើទោះបីជាសេវានិស្សិតត្រូវបានចាត់ទុកជាសេវាសំខាន់ក្នុងការគាំទ្រ និងជួយនិស្សិតឱ្យឈានទៅសម្រេចជីវិតសិក្សាថ្នាក់ឧត្តមសិក្សាឱ្យបានជោគជ័យ ដូចមានបញ្ជាក់ក្នុងសេចក្តីណែនាំរបស់អង្គភាពមានសមត្ថកិច្ចក៏ដោយ។ គ្រឹះស្ថានឧត្តមសិក្សាបានត្អូញត្អែរពីការមិនមានធនធានមនុស្សគ្រប់គ្រាន់ និងថវិកាសម្រាប់ការអនុវត្ត ថែមទាំងនៅចាត់ទុកថា សេវានិស្សិតមិនទាន់ជាផ្នែកអាទិភាពរបស់គ្រឹះស្ថានឧត្តមសិក្សានៅឡើយ។ ការពិតមួយដែលមិនមានការព្រួយបារម្ភ ឬចាប់អារម្មណ៍របស់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងមិនមានការភ័យខ្លាចថាគ្មានចំនួននិស្សិតចូលរៀនរបស់គ្រឹះស្ថានក៏ព្រោះតែនៅរៀងរាល់ឆ្នាំ ចំនួននិស្សិតដាក់ពាក្យចូលសិក្សានៅគ្រឹះស្ថានឧត្តមសិក្សារដ្ឋមួយចំនួនគឺតែងតែគ្រប់ចំនួន ឬលើសចំនួនថែមទៀតផង ស្របពេលគ្រឹះស្ថានប្រកាសឈប់ទទួលពាក្យចូលរៀន ទាំងមិនទាន់ដល់ថ្ងៃកំណត់ផង។ ទាំងនេះបង្ហាញយ៉ាងច្បាស់បន្ថែមថា គ្រឹះស្ថានឧត្តមសិក្សារដ្ឋនៅមោទនភាពលើកេរ្តិ៍ឈ្មោះ ភាពល្បីរន្ទឺ គួបផ្សំជាមួយបទពិសោធច្រើនឆ្នាំលើការងារបណ្តុះបណ្តាល ដែលមានអនុភាពអាចទាញចំណាប់អារម្មណ៍និស្សិតដោយមិនចាំបាច់ប្រឹងប្រែងផ្គាប់ចិត្ត និងចំណាយថវិកាខ្លាំងលើការគាំទ្រនិស្សិតនោះដែរ។ ការផ្តល់សេវានិស្សិតគឺនៅមិនទាន់ឆ្លើយតបហើយ ខណៈសកម្មភាពសេវាផ្សេងៗមានចំនួនតិចតួច ហើយការផ្សព្វផ្សាយពីសេវាដែលតិចនេះ មិនទាន់បានទូលំទូលាយដល់និស្សិតកំពុងសិក្សាបានដឹង និងប្រើប្រាស់នោះទេ។

និស្សិតត្អូញត្អែរពីការពុំបានដឹងពីព័ត៌មាននៃការផ្តល់សេវា និងរបៀបនៃការទទួលសេវាពីគ្រឹះស្ថាន ហើយបន្ថែមថា គ្រឹះស្ថានពុំបានយកចិត្តទុកដាក់ខ្លាំងលើការសិក្សារបស់ពួកគេនោះទេ គឺហាក់ដូចជាទុកពួកគេចោល។ ការស្រាវជ្រាវបានរកឃើញបន្ថែមទៀតថា សេវាមានតិច មិនទាន់ល្អ មិនទាន់កែសម្រួល តែការចំណាយលើសេវាកម្មផ្សេងៗបែរកើនឡើងទៅវិញ។ សេវានិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សារដ្ឋពុំទាន់មាននិរន្តភាព និងប្រសិទ្ធភាព។ សេវាតិចតួចទាំងនេះគឺធ្វើនិងរៀបចំឡើងតាមរដូវកាលតែប៉ុណ្ណោះ ដោយពុំទាន់ផែនការច្បាស់លាស់ និងរៀបចំឡើងតាមស្ថានភាពចាំបាច់ និង

មានករណីខ្លះ រៀបចំឡើងដើម្បីទាក់ទាញនិស្សិតអំឡុងពេលសិស្សផ្ដាប់បាក់ឌុបកំពុងធ្វើការពិចារណាលើការជ្រើសរើសគ្រឹះស្ថានឧត្ដមសិក្សា និងជំនាញសិក្សាសម្រាប់ឆ្នាំសិក្សាថ្មីតែប៉ុណ្ណោះ។

ជារួម ដើម្បីចូលរួមលើកកម្ពស់គុណភាពសេវានិស្សិតនៅកម្រិតគ្រឹះស្ថានឧត្ដមសិក្សា ការស្រាវជ្រាវបានបង្ហាញថាសេវានិស្សិតត្រូវមានលក្ខណសម្បត្តិមួយចំនួនដូចជា៖ រចនាសម្ព័ន្ធនិងធនធានមនុស្ស យន្តការច្រកចេញចូលតែមួយ ថវិកា និងការចូលរួម ដែលផ្នែកនីមួយៗត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងភាពច្នៃប្រឌិតខ្ពស់ស្របតាមការប្រែប្រួលនៃស្ថានគ្រឹះស្ថាន និងនិស្សិត។ ជាពិសេស ការប្រើប្រាស់ធនធានមនុស្ស។ ការប្រើប្រាស់ធនធានមនុស្សរបស់គ្រឹះស្ថានឱ្យទទួលបន្ទុកផ្នែកនេះទៀតសោត គឺជ្រើសរើសតែនិស្សិត ដោយពុំទាន់មានអ្នកជំនាញច្បាស់លាស់លើសេវាជាក់លាក់ និងត្រឹមត្រូវនៅឡើយ។ ឧទាហរណ៍៖ មន្ត្រីប្រឹក្សាផ្នែកសុខភាពផ្លូវចិត្ត និងសុខភាពជាដើម។ ពិតណាស់ថា ការផ្ដល់សេវាដោយពុំទាន់មានអ្នកជំនាញ គឺមិនត្រឹមតែមិនបានជួយឱ្យមានប្រសិទ្ធភាពលើការផ្ដល់សេវានោះទេ តែពេលខ្លះអាចនាំមកនូវគុណវិបត្តិដល់គ្រឹះស្ថានផងក៏មាន។ ការប្រើប្រាស់និស្សិតសម្រាប់ផ្ដល់សេវានិស្សិតរបស់គ្រឹះស្ថានពុំទាន់មានន័យសេចក្ដីត្រឹមត្រូវទាំងស្រុងនោះទេ បើទោះបីជាមានតែនិស្សិត ទើបដឹងតម្រូវការនិស្សិតក៏ពិតមែន តែការដោះស្រាយបញ្ហាមួយចំនួន វត្តមានអ្នកបច្ចេកទេសពិតជាសំខាន់ ដោយមិនអាចមើលរំលងបាន។ និស្សិតចូលរួមក្នុងការស្រាវជ្រាវនេះបានលើកឡើងជាញឹកញាប់ថា កំឡុងពេលសិក្សានៅឧត្ដមសិក្សាពួកគាត់ដែលជា អតិថិជនបាត់បង់កម្លាំងចិត្ត ខ្វះការប្រឹក្សាត្រឹមត្រូវ ហើយមានមិត្តភក្ដិបានបោះបង់ការសិក្សាជាបន្តបន្ទាប់ ហើយគាត់ក៏មិនទាន់ដឹងច្បាស់ថា ការសិក្សារាល់ថ្ងៃនឹងគោលដៅខាងមុខដូចម្ដេចនោះទេ។

## អនុសាសន៍

ការសិក្សានេះបានរកឃើញពីបញ្ហាប្រទាក់ក្រឡាគ្នាមួយចំនួនដែលបន្តនៅជាកង្វល់ និងមិនទាន់ស៊ីចង្វាក់គ្នានៅឡើយក្នុងក្របខណ្ឌដំណើរការ អនុវត្ត និងបង្កើនគុណភាពសេវានិស្សិតនៅគ្រឹះស្ថានឧត្ដមសិក្សា។ បើទោះបីការសិក្សាស្រាវជ្រាវនេះនៅមានកម្រិត ដោយការជ្រើសរើសគ្រឹះស្ថានឧត្ដមសិក្សារដ្ឋដែលមាននិស្សិតចូលរៀនច្រើនជាងគេ ការសិក្សានេះក៏អាចឆ្លុះបញ្ចាំង និងផ្ដល់អនុសាសន៍មួយចំនួន ដូចខាងក្រោម៖

### សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា

- ក្រសួងអប់រំ យុវជន និងកីឡា គប្បីរៀបចំការវាយតម្លៃលើគុណភាពរបស់គ្រឹះស្ថានឧត្ដមសិក្សាឱ្យក្លាយជាកាតព្វកិច្ចរបស់គ្រឹះស្ថាន។
- ក្រសួងអប់រំ យុវជន និងកីឡា គប្បីរៀបចំគោលការណ៍លើកទឹកចិត្តដល់គ្រឹះស្ថានឧត្ដមសិក្សាដែលអនុវត្តសេវានិស្សិតឈានមុខ និងល្អជាងគេ។
- ក្រសួងអប់រំ យុវជន និងកីឡា គប្បីរៀបចំគោលការណ៍ឱ្យគ្រឹះស្ថានឧត្ដមសិក្សាផ្សព្វផ្សាយជាសាធារណៈលើការផ្ដល់សេវានិស្សិត។
- ការជជែកគ្នា និងយកបញ្ហានិស្សិតមកដាក់លើតុ ដើម្បីពិនិត្យ និងសម្រេចជាសំឡេងមួយ ពិតជាត្រូវការជាចាំបាច់ ដើម្បីឱ្យការលើកកម្ពស់សេវានេះមាននិរន្តភាព និងត្រឹមត្រូវ។

### សម្រាប់គ្រឹះស្ថានឧត្ដមសិក្សា

- គ្រឹះស្ថានឧត្ដមសិក្សាគប្បីរៀបចំការស្រាវជ្រាវរាល់ដើមឆ្នាំសិក្សាពីស្ថានភាព និងតម្រូវការនិស្សិត។

- គ្រឹះស្ថានឧត្តមសិក្សាគប្បីរៀបចំរចនាសម្ព័ន្ធសេវានិស្សិតឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។
- គ្រឹះស្ថានឧត្តមសិក្សាគប្បីជ្រើសរើសអ្នកជំនាញក្នុងការប្រឹក្សាឱ្យបានត្រឹមត្រូវ។
- គ្រឹះស្ថានឧត្តមសិក្សាគប្បីធ្វើទំនើបកម្មលើការផ្តល់សេវាសិក្សា។
- គ្រឹះស្ថានឧត្តមសិក្សាគប្បីកាត់បន្ថយការផ្តល់សេវាដោយផ្ទាល់មាត់។
- គ្រឹះស្ថានឧត្តមសិក្សាគប្បីស្វែងយល់ និងជ្រើសរើសតំណាងនិស្សិតចូលរួមក្នុងការងារដឹកនាំ និងការសម្រេចចិត្តផ្សេងៗរបស់គ្រឹះស្ថាន។
- គ្រឹះស្ថានឧត្តមសិក្សាគប្បីបង្កើនទំនាក់ទំនងជាមួយសហគ្រាសឱ្យបានច្រើន។

**សម្រាប់សហគ្រាស**

- សហគ្រាសគប្បីផ្តល់ឱកាសបណ្តុះបណ្តាលការអនុវត្តការងារ និងចំណេះដឹងពីការងារ។
- សហគ្រាសគប្បីផ្តល់ឱកាសដល់និស្សិតចូលរួមហាត់ការ ទស្សនកិច្ច និងកម្មសិក្សា។
- សហគ្រាសគប្បីផ្តល់ឱកាសការងារដល់និស្សិតជួបការលំបាក និងនិស្សិតឆ្នើម។

**សម្រាប់និស្សិត**

- និស្សិតគប្បីស្វែងយល់ឱ្យបានស៊ីជម្រៅពីបរិស្ថានសិក្សានៅឧត្តមសិក្សាស្របតាមបរិបទសង្គម។
- និស្សិតគប្បីពង្រឹងសមត្ថភាពចំណេះដឹងជំនាញ ជំនាញទន់ និងបច្ចេកវិទ្យា។
- និស្សិតគប្បីចូលរួមសកម្មភាពនានារបស់គ្រឹះស្ថានដោយការទទួលខុសត្រូវខ្ពស់។

**សម្រាប់អ្នកស្រាវជ្រាវ**

ការសិក្សានេះ គឺជាការសិក្សាខ្នាតតូចដែលផ្តោតសំខាន់ទៅលើគ្រឹះស្ថានឧត្តមសិក្សារដ្ឋដែលមានចំនួនច្រើនជាងគេតែប៉ុណ្ណោះ។ ទិន្នន័យនេះការស្រាវជ្រាវនេះគឺបានដោយសារៈសំយោគពីឯកសារដែលមានស្រាប់ ការធ្វើបទសម្ភាសជាមួយថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សា និងនិស្សិតក្នុងគោលដៅ។ ដូចនេះ លទ្ធផលនៃការស្រាវជ្រាវនេះពុំមានអនុភាពវាយតម្លៃទៅគ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ក្នុងប្រទេសកម្ពុជានោះទេ។ ដើម្បីឱ្យការសិក្សាពីស្ថានភាពសេវានិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាឱ្យកាន់តែគ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅ គួរពិចារណាលើអនុសាសន៍ដូចខាងក្រោម

- ការស្រាវជ្រាវពេលក្រោយគួរធ្វើនៅចំពោះគ្រឹះស្ថានឧត្តមសិក្សាឯកជនដែលមានចំនួននិស្សិតច្រើនជាងគេ។
- ការស្រាវជ្រាវពេលអនាគតគួរស្រាវជ្រាវពីចំនួនគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន ដោយមានការចូលរួមស្រាវជ្រាវពីតួអង្គដៃគូអភិវឌ្ឍ និងសហគ្រាស។
- ការស្រាវជ្រាវពេលក្រោយគួរធ្វើការស្រាវជ្រាវការផ្តល់សេវារបស់គ្រឹះស្ថានឧត្តមសិក្សាឯកជនដែលមានតម្លៃសិក្សាផ្សេងពីគ្នា។

## សេចក្តីថ្លែងអំណរគុណ

ការស្រាវជ្រាវនេះទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីសាកលវិទ្យាល័យរដ្ឋគោលដៅ ការណែនាំពីលោកបណ្ឌិត សំ ច័ន្ទការុណ នាយករងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងលោកបណ្ឌិត ម៉ុក សារ៉ុម អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាថ្នាក់ដឹកនាំ មន្ត្រី

និស្សិតនៃគ្រឹះស្ថានឧត្តមសិក្សា ដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ។ អ្នកនិពន្ធក៏សូមថ្លែងអំណរគុណដល់និពន្ធនាយក និងអ្នកត្រួតពិនិត្យជំនាញអនាមិករបស់ទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម សម្រាប់មតិកែលម្អលើអត្ថបទស្រាវជ្រាវនេះ។ ខ្លឹមសារអត្ថបទនេះគឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ស្ថាប័នរបស់អ្នកនិពន្ធកំពុងបំពេញការងារ ឬនិន្នាការនយោបាយរបស់ក្រុមណាមួយឡើយ។

## ឯកសារយោង


Accreditation Committee of Cambodia. (2009). *ស្តង់ដារអប្បបរមាសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជា* [Mininum Standards for Accrediation of Higher Education Institution].

Accreditation Committee of Cambodia. (2013).*ស្តង់ដារអប្បបរមាសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជា* [Mininum Standards for Accrediation of Higher Education Institution]

American Association of Colleges and Universities. (2002). *Greater expectation: A new vision for learning as a nation goes to college*. https://www.proquest.com/scholarly-journals/greater-expectations-new-vision-learning-21st/docview/216592510/se-2

Arnold, K., Altbach, P. G., & King, I. C. (2014). *College student development and academic life: Psychological, intellectual, social and moral issues*. Routledge.

Audin, K., Davy, J., & Barkham, M. (2003). University quality of life and learning (UNIQoLL): An approach to student well-being, satisfaction and institutional change. Journal of Further and Higher Education, 27(4), 365-382. https://doi.org/10.1080/0309877032000128073

Ayres, D. M. (2000). *Anatomy of a crisis: Education, development, and the state in Cambodia, 1953-1998*. University of Hawaii Press.

Azfredrick, E. C. (2015). Use of counselling services by school-attending adolescent girls in Nigeria. *Journal of Child & Adolescent Mental Health, 27*(1), 1-10. https://doi.org/10.2989/17280583.2014.953955

Ban, T., & Heng, K. (2023). Improving the quality of Cambodian higher education: Key challenges and suggestions. *Cambodian Journal of Educational Research, 3*(2), 35-61. https://doi.org/10.62037/cjer.2023.03.02.03

Bjorklund, S. A., Parente, J. M., & Sathianathan, D. (2004). Effects of faculty interaction and feedback on gains in student skills. *Journal of Engineering Education, 93*(2), 153-160. https://doi.org/10.1002/j.2168-9830.2004.tb00799.x

Braun, V., & Clarke, V. (2006). Using thematic analysis in psychology. *Qualitative Research in Psychology, 3*(2), 77-101. https://doi.org/10.1191/1478088706qp063oa

Bresciani, M. (2011). *Making assessment meaningful: What new student affairs professionals and those new to assessment need to know*. National Institute for Learning Outcomes Assessment.

Burge, L. (2018). Supporting student transition and early engagement: An online induction program. *JANZSSA: Journal of the Australian and New Zealand Student Services Association, 26*(2), 79-85. https://search.informit.org/doi/10.3316/informit.476061061893193

Chealy, C. (2009). Higher Education in Cambodia. In Y. Hirosato & Y. Kitamura (Eds.), *The Political Economy of Educational Reforms and Capacity Development in Southeast Asia: Cases of Cambodia, Laos and Vietnam* (pp. 153-165). Springer Netherlands. https://doi.org/10.1007/978-1-4020-9377-7_10

Chealy, C., & Leang, U. (2019). The internationalization of higher education in Cambodia. *Insight: Cambodia Journal of Basic and Applied Research, 1*(1). https://doi.org/10.61945/cjbar.2019.1.1.edi

Chepchieng, M. C., Kiboss, J. K., Sindabi, A., Kariuki, M. W., & Mbugua, S. N. (2006). Students' attitudes toward campus environment: A comparative study of public and private universities in Kenya. *Educational Research and Reviews, 1*(6), 174-179. https://academicjournals.org/journal/ERR/article-full-text-pdf/D66B5103510

Chepchieng, M. C., Mbugua, S. N., & Kariuki, M. W. (2006). *University students' perception of lecturer-student relationships: a comparative study of Public and Private Universities in Kenya* (Vol. 1).

Ciobanu, A. (2013). The role of student services in the improving of student experience in higher education. *Procedia - Social and Behavioral Sciences*, *92*, 169–173. https://doi.org/10.1016/j.sbspro.2013.08.654

Clayton, T. (2006). *Language choice in a nation under transition: English language spread in Cambodia*. Springer. https://www.researchgate.net/publication/321610812_Language_Choice_in_a_Nation_Under_Transition_English_Language_Spread_in_Cambodia

Clayton, T., & Ngoy, M. (1997). *Asian higher education: An international handbook and reference guide*. Greenwood Press.

Clayton, T. (1998). Building the new Cambodia: Educational destruction and construction under the Khmer Rouge, 1975–1979. *History of Education Quarterly, 38*(1), 1-16. https://www.jstor.org/stable/369662?origin=crossref

Clift, P. (2003). *Student support and retention: Models of explanation and good practice*. University of Manchester and UMIST. https://documents.manchester.ac.uk/display.aspx?DocID=10064

Cohen, L., Manion, L., & Harrison, K. (2007). *Research methods in education* (6th ed.). Routledge. https://doi.org/10.4324/9780203029053

Conefrey, T. (2018). Supporting first-generation students' adjustment to college with high-impact practices. *Journal of College Student Retention: Research, Theory & Practice, 23*(1), 1–34. https://doi.org/10.1177/1521025118807402

Creswell, J. W. (2012). *Educational research: Planning, conducting, and evaluating quantitative and qualitative research* (4th ed.). Pearson.

Dickson, O. M., Brandford, B., Prosper, D. D., & Esther, B. N. (2024). A systematic review of students' support services provision in higher education (SSSPiHE) in sub-Saharan Africa. *Cogent Education, 11*(1), 1-16. https://doi.org/10.1080/2331186X.2024.2351747

Emily, M. A. (2018). Assessment of student services in a state university for policy recommendations. *The Normal Light, 12*(2), 145-167. https://doi.org/10.56278/tnl.v12i2.1005

Julal, F. S. (2015). Predictors of undergraduate students' university support service use during the first year of university. *British Journal of Guidance & Counselling, 44*(4), 371-381. https://doi.org/10.1080/03069885.2015.1119232

Ngara, E. (1995). *The African university and its mission for improving the delivery of education.* Institute of Southern African Studies.

Oketch, M. (2016). Financing higher education in sub-Saharan Africa: Some reflections and implications for sustainable development. *Higher Education, 72*(4), 525–539. https://doi.org/10.1007/s10734-016-0044-6

Gerdes, H., & Mallinckrodt, B. (1994). Emotional, social, and academic adjustment of college students: A longitudinal study of retention. *Journal of Counseling & Development, 72*(3), 281–288. https://doi.org/10.1002/j.1556-6676.1994.tb00935.x

Giddan, N. S. (1988). *Community and social support for college students*. Thomas.

Habtom, G. K. (2020). An overview of the challenges of agricultural research in Sub-Saharan Africa: The case of Eritrea. *Journal of Agricultural Economics, 6*(3), 865–887. https://www.academia.edu/74267190/AN_OVERVIEW_of_the_CHALLENGES_of_AGRICULTURAL_RESEARCH_in_SUB_SAHARAN_AFRICA_THE_CASE_of_ERITREA_AN_OVERVIEW_of_the_CHALLENGES_of_AGRICULTURAL_RESEARCH_in_SUB_SAHARAN_AFRICA_THE_CASE_of_ERITREA

Hangchuon, N. (2016). *កំណែទម្រង់វិស័យអប់រំនៅកម្ពុជា៖ ឆ្ពោះទៅកាន់សង្គមពុទ្ធិ និង វិបុលភាព*[Education reform in Cambodia: Toward knowledge-based society and prosperity]. ភ្នំពេញ.

Heng, K., Doeur, B., & Din, L. (2023). Promoting higher education quality in Cambodia: Challenges and recommendations. *Cambodian Journal of Educational Research, 3*(1), 92109. https://doi.org/10.62037/cjer.2023.03.01.05

Heng, K., & Sol, K. (2023). Challenges facing higher education in Cambodia and ideas for reform. *Cambodian Journal of Educational Research, 3*(1), 1-19. https://doi.org/10.62037/cjer.2023.03.01.01

Heng, K. (2024). Challenges and developments in university research in Cambodia: A case study of two universities. *Higher Education, 87*(6), 1593-1613. https://doi.org/10.1007/s10734-023-01080-2

Hill, Y., Lomas, L., & MacGregor, J. (2003). Students′ perceptions of quality in higher education. *Quality Assurance in Education, 11*(1), 15–20. https://doi.org/10.1108/09684880310462047

Heng, K. (2014). The effects of faculty behaviors on the academic achievement of first-year Cambodian urban university students. *Educational Research and Policy Practice, 13*, 233–250. https://doi.org/10.1007/s10671-013-9159-z

Henri, L. (1995). *Report on higher education in Cambodia*. UNESCO.

Husain, F., Qasim, H. A., & Sheikh, K. H. (2003). An analysis of public expenditure on education in Pakistan. *The Pakistan Development Review, 42*(4), 771–780. https://doi.org/10.30541/v42i4IIpp.771-780

Jaswinder, K., Mhairi, M., & Hong, W. (2008). How effective are institutional and departmental systems of student support? Insights from an investigation into the support available to students at one English university. Routledge. https://doi.org/10.1080/13596740802346472

Johnson, C., Gitay, R., Salam, A. G., Bensaid, A., Ismail, A., Al-Tameemi, R. A. N., Rpmanowski, M. H., Fakih, B. M. K., & Hazaa, K. A. (2022). Student support in higher education: Campus service utilization, impact, and challenges. *Cell Press*, 1-13.

Khan, M. A. (2009). Human resource development and financing issues: A South Asian perspective. *SAARC Journal, 5*(1), 1-17. http://dx.doi.org/10.22617/TCS179082

Kingdom of Cambodia. (1949). *ព្រះរាជក្រឹត្យលេខ១៧ នស ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៤៩ ស្តីពីការបង្កើត វិជ្ជាស្ថានជាតិយុត្តិធម្មសាស្ត្រនិងសេដ្ឋសាស្ត្រ* [Royal Degree on the Esblishment of the National law and Economic].

Kingdom of Cambodia. (1960). *ព្រះរាជក្រមលេខ៣៦៧-ន.ស ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៦០ ស្តីពីការបង្កើតសាកលវិទ្យាល័យខេមរភូមិន្ទ* [Royal Degree on the esblishment of the Royal Khmer University].

Kingdom of Cambodia. (2015). *ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីលក្ខន្តិក:គតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល* [Royal Degree on the Criterias of Public Administrative Institute].

Kingdom of Cambodia. (2003). *ព្រះរាជក្រឹត្យលេខនស/រកត/០៣០៣ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា* [Royal Degree on the Recognition of the Qualiity of the Higher Education Institution].

Kingdom of Cambodia. (2007). *ព្រះរាជក្រមលេខនស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ច្បាប់ស្តីពីការអប់រំ* [Royal Degree about Law on Education].

Kingdom of Cambodia.(2018). *ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិក:គតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល* [Royal Degree on the Revise of  Criterias of Public Administrative Institute date August 8, 2015].

Kasmad, K. M., Muhammad, A. M., Andi, N. S., & Syamjaya, S. M. (2021). One Stop Service: A way to reform public service. *IEOM Society International, 7*(11), 44844491. https://doi.org/10.46254/AN11.20210795

Katrevich, A. V., & Aruguete, M. S. (2017). Recognizing challenges and predicting success in first-generation university students. *The Journal of STEM Education: Innovations and Research, 18*(2), 40-44. https://www.researchgate.net/publication/340754383_Recognizing_Challenges_and_Predicting_Success_in_First-Generation_University_Students

Kehm, B. M., Larsen, M. R., & Sommersel, H. B. (2019). Student dropout from universities in Europe: A review of empirical literature. *Hungarian Educational Research Journal, 9*(2), 147–164. https://doi.org/10.1556/063.9.2019.1.18

Leng, P. (2010). Students′ perceptions toward private sector of higher education in Cambodia. *Southeast Asian Studies*.

Leng, P. (2015). Mutuality in Cambodian international university partnerships: Looking beyond the global discourse. Springer Science+Business Media Dordrecht. https://doi.org/10.1007/s10734-015-9952-0

Lim, D. (1999). Quality assurance in higher education in developing countries. *Assessment and Evaluation in Higher Education, 24*(4), 379-389. https://doi.org/10.1080/0260293990240402

Mackie, S. (2001). Jumping the hurdles: Undergraduate student withdrawal behavior. *Innovations in Education and Training International, 38*(3), 256-276. https://www.researchgate.net/publication/248913343_Jumping_the_Hurdles__Undergraduate_Student_Withdrawal_Behaviour

Mastoi, A. G., Hai, L. X., & Saengkrod, W. (2019). Higher education service quality based on students' satisfaction in People's Republic of China. *Journal of Education and Practice, 6*(10), 109-121. https://www.researchgate.net/publication/331383676_Higher_Education_Service_Quality_based_on_Students'_Satisfaction_in_People's_Republic_of_China

McKenzie, K., & Schweitzer, R. (2001). Who succeeds at university? Factors predicting academic performance in first-year Australian university students. *Higher Education Research and Development, 20*(1), 21-33. https://doi.org/10.1080/07924360120043621

Mitchell, R., Rose, P., & Asare, S. (2020). Education research in sub-Saharan Africa: Quality, visibility, and agendas. *Comparative Education Review, 64*(3), 363383. https://doi.org/10.1086/709428

MoEYS. (2014). *ចក្ខុវិស័យឧត្រមសិក្សា ២០៣០* [Higher Education's Vision 2030]. Ministry of Education, Youth and Sport.

MoEYS.(2017). *សន្និបាតអប់ះបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២២-២០២៣ និងលើកទិសដៅការងារ ឆ្នាំសិក្សា២០២៣-២០២៤* [Education Congress: The Summary of Education, youth and sport performance in the Academic Year 2022-2023 and Goal for the Academic Year 2023-2024′].Ministry of Education, Youth and Sport.

MoEYS. (2019). *ផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៩-២០២៣* [ Educational Strategic Plan 2019-2023].Ministry of Education, Youth and Sport.

MoEYS. (2024). *សន្និបាតអប់រំ យុវជន និងកីឡា*.[Education Congress: The Education, youth and sport performance in the academic year 2022-2023 and goal for the academic year 2016-2017].Ministry of Education, Youth and Sport.

MoEYS. (2024). *កំណែទម្រង់ឧត្តមសិក្សា* [Higher Education Reform].Ministry of Education, Youth and Sport.

Moeurn, C. (2017). *School-to-university transition*. Royal University of Phnom Penh.

Montgomery, M. J., & Côté, J. E. (2006). College as a transition to adulthood. Blackwell Publishing Ltd.

Mulaudzi, I. C. (2023). Challenges faced by first-year university students: Navigating the transition to higher education. *Journal of Education and Human Development, 12*(2), 79–87. https://doi.org/10.15640/jehd.v12n2a8

Nault, R. (2008). Making the most of Cambodia's human resources. *Cambodia Development Review, 12*(2), 9-14.

NASPA. (2008). *Student affairs administrators in higher education*. National Association of Student Personnel Administrators, Inc.

NASPA-Student Affairs Administrators in Higher Education. (2012). *Considering a career in student affairs?* Retrieved from http://www.naspa.org/career/default.cfm.

Ngara, E. (1995). *The African university and its mission for improving the delivery of education*. Institute of Southern African Studies.

Oketch, M. (2016). Financing higher education in sub-Saharan Africa: Some reflections and implications for sustainable development. *Higher Education, 72*(4), 525–539. https://doi.org/10.100\7/s10734-016-0044-6

Pantages, T. J., & Creedon, C. F. (1978). Studies of college attrition: 1950–1975. *Review of Educational Research, 48*, 49–101. https://doi.org/10.2307/1169909

Patton, M. Q. (2002). *Qualitative research & evaluation methods*. Sage Publications.

Perry, C. J., Lausch, D. W., McKim, C., & Weatherford, J. (2022). Knowledge, use, and perceived value of university student services: International and domestic student perceptions. *Journal of International Students, 10*(3), 613-628. https://doi.org/10.32674/jis.v9i4.269

Royal Government of Cambodia. (1984).*អនុក្រឹត្យលេខ២៤អនក្រ ចុះថ្ងៃ០៨ ខែធ្នូ ឆ្នាំ១៩៨៤ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស គ្របដណ្តប់លើការសិក្សា* [*Anukret No. 24 ANKr dated December 8, 1984 on the Establishment and Management of Higher Education and Specialized Education Institutions Covering Studies*.]

Royal Government of Cambodia. (1992). *អនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស* [*Anukret No. 01 ANKr dated January 20, 1992 on the Establishment and Management of Higher Education and Specialized Education Institutions*.]

Royal Government of Cambodia. (2017).*អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៧* [Sub Degree in the establishment of One Stop Service Mechanism for Administrative Service at Sun National Level].

Sam, R., Zain, A. N. M., & Jamil, H. (2012). Establishment of institutional policies for enhancing education quality in Cambodian universities. *International Journal of Higher Education, 1*(1), 112-127. https://doi.org/10.5430/ijhe.v1n1p112

Santos, G., Marques, C. S., Justino, E., & Mendes, L. (2020). Understanding social responsibility′s influence on service quality and student satisfaction in higher education. *Journal of Cleaner Production*. https://doi.org/10.1016/j.jclepro.2020.120597

Sandeen, A., & Barr, M. (2006). *Critical issues for student affairs: Challenges and opportunities*. Jossey-Bass.

Selim, A., & Muhammad, M. (2014). Measuring service quality of a higher educational institute towards student satisfaction. *American Journal of Educational Research, 2*(7), 447–455. https://www.researchgate.net/publication/268979958_Measure_Service_Quality_of_a_Higher_Educational_Institute_towards_Student_Satisfaction

Shaun, A. H., & Stephen, J. Q. (2009). *Student engagement in higher education*. Routledge.

Shek, D. T. L., & Leung, H. (2015). *Promoting service leadership qualities in university students: Quality of life in Asia*. Springer Science + Business Media Singapore. https://doi.org/10.1007/978-981-287-515-0

Siu, O. L., Bakker, A. B., & Jiang, X. (2014). Psychological capital among university students: Relationships with study engagement and intrinsic motivation. Journal of Happiness Studies, 15, 979-994. https://doi.org/https://doi.org/10.1007/s10902-013-9459-2

Sloper, D. (1999). Higher education in Cambodia: An overview and key issues. In D. Sloper (Ed.), *Higher education in Cambodia: The social and educational context for reconstruction*. UNESCO PROAP.

Sok, S. and Bunry, R. (2024), "Higher Education in Cambodia", Pe Symaco, L. (Ed.) *Higher Education in Southeast Asia* (International Perspectives on Education and Society, Vol. 49), Emerald Publishing Limited, Leeds, 5-18. https://doi.org/10.1108/S1479-367920240000049002

The World Bank. (1994). *Higher education: The lesson of experience*. (World Bank Stock No. 12745). The World Bank.

The World Bank. (1997). *Vietnam education financing*. (World Bank Stock No.14023). The World Bank.

The World Bank. (2000). *Higher education in developing countries: Peril and promise*. (World Bank Stock No. 14630). The World Bank.

Tilak, J. B. G. (2003). Higher education and development in Asia. *Journal of Education Planning and Administration, 17*(2), 151-173. https://www.researchgate.net/publication/44832162_Higher_education_and_development_in_Asia

Tinto, V. (1993). *Leaving college: Rethinking the causes and cures of student attrition* (2nd ed.). The University of Chicago Press.

Turner, M. (2012). Decentralization, politics and service delivery. *Public Management Review, 14*(2), 197–215. https://doi.org/10.1080/14719037.2012.657960

Ty, Y., & Samnang, S. (1999). ). *ប្រវត្តិនៃការអប់រំ៖ បឋម និងមធ្យមសិក្សានៅកម្ពុជា (ពីបុរាណរហូតដល់បច្ចុប្បន្នកាល (១៩៩៨-១៩៩៩)* [History of Education: From Primary to Secondary (From Early Age to the Current (1998-1999)]. Phnom Penh.

Un, L., & Sok, S. (2019). *Higher education governance in Cambodia: An update*. Global, Regional and National Developments. https://www.academia.edu/12068246/Higher_Education_Governance_in_Cambodia

UNESCO. (1955). *Compulsory education in Cambodia, Lao, and Vietnam*. Switzerland. https://unesdoc.unesco.org/ark:/48223/pf0000002901

UNESCO. (1998). *World declaration on higher education for the twenty-first century: Vision and action*. Author. Retrieved from http://mirror-japan.unesco.org/education/educprog/wche/declaration_eng.htm

UNESCO. (2009). *Student affairs and services in higher education: Global foundations, issues and best practices*. Paris, France. https://unesdoc.unesco.org/ark:/48223/pf0000183221

Whitt, E., Edison, M. I., Pascarella, E. T., Terenzini, P. T., & Nora, M. (2001). Impact of college on students. *Journal of Higher Education, 12*(2), 172–204.

Williams, J. H., Kitamura, Y., & Keng, C. S. (2016). *Higher education in Cambodia: Expansion and quality improvement*. Palgrave Macmillan. https://doi.org/10.1057/9781137456007_9

World Conference on Higher Education. (1998). *Higher education in the twenty-first century: Vision and action. World Declaration on Higher Education for the Twenty-First Century: Framework for Priority Action for Change and Development in Higher Education*. UNESCO. https://unesdoc.unesco.org/ark:/48223/pf0000141952

Yong, T., & Sorn, S. (1999). *ប្រវត្តិនៃការអប់រំ៖ បឋម និងមធ្យមសិក្សានៅកម្ពុជា (ពីបុរាណរហូតដល់បច្ចុប្បន្នកាល (១៩៩៨-១៩៩៩)* [History of education: primary and secondary education in Cambodia (From the past until present 1998-1999)].